# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ដោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេពសត្ថា ហួត-តាត
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| សាស្ត្រាចារ្យ ហ្វ្រង់ស្វា ម៉ារទីនី | ពិធីប្រគល់សារាចារលីដាន់ខ្ពស់ពីលំដ្ឋាភិបាលខ្មែរ | ១ |
| លោក ពែ-ប៊ុក តាយបញ្ជី | ប្រជុំសុភាសិតអ្នកនិពន្ធក្រេក | ៩ |
| លោកអាចារ្យ ឌិញ-ប្រាជ្ញ | ទំនៀមធ្វើស្រែនៅកម្ពុជាក្រោម (កូសាំងស៊ីន) | ១៨ |
| អ្នកឧកញ៉ាព្រះឃ្លាំង ងិន | រឿងភោគកុលកុមារ (តពីលេខ ១២ ឆ្នាំ ១៩៥៨) | ២៣ |
| អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន | រឿងសាមកុក (តពីលេខ ១២ ឆ្នាំ ១៩៥៨) | ៣៧ |
| ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ | ការផ្សងគ្រាន់ផលអ្នកប្រឡងជាប់ | ៤៩ |
| **ផ្នែកសាសនា** | | |
| លោកគ្រូចៅអធិការ ឯក-ញឹម វត្តរលួស (សៀមរាប) | ពិធីបុណ្យបញ្ចុះធាតុលោកគ្រូព្រះសព សុក-ខូច | ៥២ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ពន្ធអាស៊ីទូប (តពីលេខ ១២ ឆ្នាំ ១៩៥៨) | ៥៦ |
| **កំណត់ទិនប្បវត្តិការណ៍** | | |
| ឃុនសិរីមេធី ស្រី-អ៊ូ | ពុទ្ធប្បវត្តិសង្ខេប (តពីលេខ ១២ ឆ្នាំ ១៩៥៨) | ៦៦ |
| ក្រសួងធម្មការ | ការតាំងចៅអធិការថ្មី | ៧៥ |


ឆ្នាំទី ២១ — លេខ ១ ខែមករា ឆ្នាំ ១៩៥៩ — ដំឡៃជាវ ១ ឆ្នាំ ៩៦ រៀល ។

BUDDHIST INSTITUTE LIBRARY

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Satthā So-Hay membre de la Commission du Tripitaka


## TABLE DES MATIÈRES

### Partie littéraire :


| | | page |
|---|---|---|
| Prof. François Martini Conseiller aux Cultes | Cérémonie de la remise de l'E. S. P. au gouvernement combodgien...... | 1 |
| M. Ray-Buc chef comptable | Recueil de maximes des écrivains grecs | 9 |
| Monsieur Dinh-Prach | Travaux des champs des cambodgiens de cochinchine.................... | 18 |
| Neak Oknha Brah khleang Nong | "Bhog kul kumâr" (en vers) (suite de nº 12 du 1948) ................ | 27 |
| Neak Okhna Vipularājā sena Nou-kan Député | Histoire de Sam kok (suite de nº 12 du 1948)........................ | 37 |
| Commission des Mœurs et coutûmes | Lauréats des concours institués par la Commission................ | 49 |


### Partie religieuse:


| | | |
|---|---|---|
| Vén. Chau Adhikār Ek-Nhim Vatt Rolous (Siem-reap) | Cérémonie des cendres du feu Vén. Sok Nuon...... ................... | 52 |
| Luong Nibandhamantrî Nhok-Thèm | Lumière de l'Asie (suite de nº 12 du 1948)........................ | 56 |


### Notes et chroniques


| | | |
|---|---|---|
| Khun Sirimedhi Srey-Ou | Buddhappavatti sankhepa (suite de nº 12 du 1948)................. | 66 |
| Ministère des Cultes | Nomination de nouveaux Chau Adhikâr ........................ | 74 |



21e Année: Nº 1 Janvier 1949 — Prix d'abonnement 96$00 par an.

# ពិធីប្រគល់សាលាបាលីជាន់ខ្ពស់

កាលពីថ្ងៃសុក្រ ៣១ ធ្នូ ១៩៤៨ វេលាសៀលម៉ោង ៤ មានពិធីមួយជាឱឡារិក នៅសាលាបាលីជាន់ខ្ពស់ ដោយមានអគ្គតំណាងបារាំង លោកគុមីសែរដឺឡារេពុយព្លិក និងអ្នកតំណាងរាជរដ្ឋាភិបាលខ្មែរ ព្រមទាំងព្រះសង្ឃសមណសក្តិផង គឺព្រះសង្ឃនាយកទាំងពីរគណៈ សម្តេចព្រះធម្មលិខិតអនុក្កមប្រឹក្សា ព្រះពោធិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់ អស់លោកសាស្ត្រាចារ្យ និងព្រះសង្ឃជាសិស្សានុសិស្សគ្រប់ថ្នាក់ បានចូលទៅជួបជុំនៅថែវរៀនកណ្ដាលកន្លែងមុខប៊ុយរ៉ូការរបស់សាលា ។

នៅឱកាសជាសុភមង្គលនេះ គេបានសង្កេតឃើញលោកម៉ារ៉ូទីទី ប្រឹក្សាក្រសួងធម្មការ និងអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ តំណាងលោកគុមីសែរដឺឡារេពុយព្លិក និងភ្នាក់ងារខ្លះខាងពុទ្ធសាសនបណ្ឌិត្យ លោកអ្នកឧកញ៉ាពិភក្ដិសាសនៈ រដ្ឋមន្ត្រីក្រសួងធម្មការ តំណាងខាងព្រះរាជរដ្ឋាភិបាលខ្មែរ ព្រមដោយមន្ត្រីភ្នាក់ងារក្នុងក្រសួងធម្មការ ។ លុះជួបជុំព្រមគ្នាហើយ ទើបលោកម៉ារ៉ូទី តំណាងលោកគុមីសែរ ថ្លែងសុន្ទរកថាមួយ ដើម្បីបញ្ចប់ពិធីប្រគល់សាលាបាលីជាន់ខ្ពស់ទៅរដ្ឋាភិបាលខ្មែរ ។ ដល់ចប់សុន្ទរកថា លោកអ្នកឧកញ៉ាពិភក្ដិសាសនៈ តំណាងរាជរដ្ឋាភិបាលខ្មែរ បានពោលពាក្យថ្លែងអំណរគុណ និង -

ជំនឿគុណចំពោះរដ្ឋាភិបាលបារាំងសែស ព្រមទាំងសំដែងសេចក្ដីមេត្រី ស្មោះត្រង់ចាស់គ្នាទៅវិញទៅមក ដោយសារគោល ជាតំណាងតាងខាង នៃរដ្ឋាភិបាលខ្មែរ ។

ឯសុន្ទរកថា របស់អ្នកតំណាងលោកកុម្មីស្ស៊ែរដឹឡារេពុប្លិកនោះ មានសេចក្ដីពីរោះក្បោះក្បាយ ដូចមានសេចក្ដីប្រែជាខេមរភាសាតទៅនេះ

សុន្ទរកថា

ព្រះតេជព្រះគុណម្ចាស់

ព្រះករុណាទាំងឡាយ

ព្រះបាទម្ចាស់

លោក-អ្នកទាំងឡាយ

ខ្ញុំករុណា ខ្ញុំបាទ សូមផ្ដើមថ្លែងអំពីសេចក្ដីរំភើបក្នុងចិត្ត ព្រមទាំងបីតិរីករាយដ៏ពន្លឹករបស់ខ្ញុំករុណា ខ្ញុំបាទ ប្រគេន-ជូនដល់ព្រះករុណា ទាំងអស់លោកជាទីសណ្ដាប់—

រយៈ ៨ ថ្ងៃមកហើយ ប្រទេសបារាំងសែស ដែលជាគូសុចរិត ស្មោះត្រង់នឹងកិច្ចសន្យារបស់ខ្លួន បានទទួលស្គាល់ជាផ្លូវការ ចំពោះ ឯករាជ្យរបស់ប្រទេសកម្ពុជា ដោយតាមអ្នកតំណាងរបស់ប្រទេសបារាំង-សែស គឺលោកកុម្មីស្ស៊ែរដឹឡារេពុប្លិក បានបញ្ជាក់ឡើងនាត់ថែងទៀតចំពោះ វិមានណាយោធនសួតថ្មី ដែលសព្វថ្ងៃឃើញថាពុំមានគំនិតអស់ឯកអ្វីឡើយ ។

វិធានការដំបូង គឺបង្កើតគម្រូជាក់ស្តែង ដែលបង្ហាញឲ្យឃើញវិធីការដណ្តើមយកនៃរដ្ឋាភិបាលបារាំងសែស គឺពិធីប្រគល់សាលាបាលីជាន់ខ្ពស់ ជូនទៅរដ្ឋាភិបាលខ្មែរ ហេតុនេះហើយបានជាខ្ញុំករុណា ខ្ញុំបាទមានរំភើបក្នុងចិត្តនឹងបីតិត្រេកអរណាស់ ។ បានជាខ្ញុំមានចិត្តរំភើបដល់ម្ល៉េះ ដោយខ្ញុំករុណាជាជាតិបារាំងសែសម្នាក់ក្រោយបង្អស់ ដែលនឹងបានជាអធិបតី នៅប្រែព្រះតេជព្រះគុណចាន់ហ្មួន សាលាបាលីជាន់ខ្ពស់ក្នុងក្រសួងរាជការ នៃការស្ថាបនានេះ ។ ខ្ញុំករុណា ខ្ញុំបាទពេញចិត្តណាស់ ដោយមានដោនក់ស្នា នូវការដែលលោកកុម្មីស្សែរបានចាត់ខ្ញុំករុណា ខ្ញុំបាទមកជាអ្នកតំណាងក្នុងពិធីនេះ ដែលសម្តែងឲ្យឃើញផ្ទៃថ្មីមួយ គឺសេចក្តីទុកចិត្តនិងមេត្រីភាព ដែលជាបច្ច័យនាំឲ្យកើតសហការបារាំង-ខ្មែរឡើង ។

បច្ចាមិត្តរបស់យើងសងខាង មុខជានឹងពោលរិះគន់ ព្រោះយើងកែងមានសត្រូវទាំងសងខាង! ប៉ុន្តែជាការផលប្រយោជន៍ដែលនឹងបញឈ្មោះបច្ចាមិត្តអស់នោះ បច្ចាមិត្តរបស់យើងទាំងសងខាងមុខជានឹងពោលថា សាលាបាលីជាន់ខ្ពស់! ខាងចំណែកបារាំងសែសមានសំនួរដូច្នេះ តើមានប្រយោជន៍អ្វី បើបារាំងសែសទុកវិជ្ជាស្ថាននេះគេទៅ ហើយវិជ្ជាស្ថាននេះអាចឲ្យផលអ្វីគេបាន?

មិនមែនប្រឌិតពុទ្ធដីកា ព្រះករុណាទាំងឡាយដែលជាព្រះសង្ឃក្នុងព្រះពុទ្ធសាសនានោះទេ ។

ខ្ញុំករុណា ខ្ញុំបាទ គ្រាន់តែសូមចង្អុលបង្ហាញសេចក្ដីសំខាន់របស់សាលាបាលីជាន់ខ្ពស់ដូចតទៅនេះ

នៅលោកិយនេះ គេតែងស្គាល់សញ្ញាល័ក្ខណ៍ដ៏ជាក់ស្ដែងមួយនៃប្រទេសកម្ពុជា ដែលប្រកបដោយភាពមួយជាចំឡែក ទាំងខាងសីលធម៌ ទាំងខាងសង្គម ជាទីដ៏ប្រសើរលើស ដែលព្រះសង្ឃពុទ្ធសាសនាបានកាន់កាប់ក្នុងសង្គមជាតិខ្មែរ ។

ដូច្នេះហើយ បានជាព្រះសង្ឃដែលថ្លៃថ្លាខាងចំណេះចេះដឹងច្រើនមានកិត្តិយសជាងព្រះសង្ឃឯទៀតៗ ក្នុងព្រះរាជាណាចក្រនេះសុទ្ធសឹងតែចេញទៅពីសាលាបាលីជាន់ខ្ពស់នេះទាំងអស់ ។

មិនចាំបាច់ធ្វើជាអ្នកពិនិត្យការដ៏ម៉ត់ចត់ ទាំងមិនចាំបាច់ស្នាក់នៅក្នុងស្រុកខ្មែរយូរយារដូចអ្នកការរដ្ឋបាល ឬខាងទាហាននោះទេ ទើបសំគាល់ឃើញថា ព្រះសង្ឃពុទ្ធសាសនាមានឥទ្ធិពលដ៏ជ្រាលជ្រៅទៅលើប្រជាជនជាតិខ្មែរ ។

ឯការត្រួតត្រាសាលាបាលីជាន់ខ្ពស់នេះ ខ្ញុំករុណា ខ្ញុំបាទ មិនសំដៅដល់របៀបត្រួតត្រាប៉ូលិសទេ គឺសំដៅដល់របៀបត្រួតត្រាខាងផ្លូវវិជ្ជាសាស្ត្រនិងវិន័យ ទាំងខាងការត្រួតត្រាការបោះពុម្ពសៀវភៅរៀន

ដោយពួកអ្នកប្រាជ្ញបារាំងសែស ពុងឌីចេរីប្រទេស មានអ្នកតំណាងសាលាបារាំងសែសពុងឌីចេរីប្រទេស ជាបុគ្គលិកមានឥទ្ធិពល ជាអ្នកដឹកនាំយ៉ាងសំខាន់ នូវកិច្ចការពារនៃវប្បធម៌បារាំងសែស ពីព្រោះការធ្វើឲ្យព្រះសង្ឃនិយមកម្ពុជាបាន ក៏ទុកដូចជាធ្វើឲ្យប្រជាជនទាំងមូលនិយមកម្ពុជាបានយ៉ាងពិតប្រាកដ ។ ហេតុដែលនាំឈប់ខ្មែរនេះទៅចុះ ដើម្បីប្រគល់ការត្រួតត្រាសាលាបាលីជាន់ខ្ពស់ទាំងមូល ដល់រដ្ឋាភិបាលខ្មែរវិញ តើការនេះបញ្ចេញឲ្យឃើញជាក់ស្តែងនូវការជឿទុកចិត្ត និងសេចក្តីសុចរិតស្មោះត្រង់ នៃប្រទេសបារាំងសែសយ៉ាងណាទៅ?

តើមានប្រយោជន៍ដែរឬទេ បើរំលឹកដល់កាលសម័យ ដែលគេបានបង្កើតសាលាបាលីជាន់ខ្ពស់នេះឡើង ព្រោះការស្ថាបនានេះ ជាគំនិតបារាំងសែសផ្តើមឡើងជាដំបូង?

មុនការគេសាងសាលានេះឡើង ពុំមានទីប្រជុំរៀនសូត្រដែលបានរៀបចំត្រួតត្រាស្រួលបួលទេ ម្ល៉ោះហើយ ព្រះសង្ឃក្មេងៗ ដែលល្អាសវៃខាងជាតិខ្មែរ និងជាតិលាវ តែងនិមន្តទៅកាន់ប្រទេសសៀម ដើម្បីសិក្សាបំពេញវិជ្ជាខាងព្រះពុទ្ធសាសនា ។ រឿងនេះគួរឲ្យមានអាម៉ាស់ ដល់កិត្តិនាមនៃបណ្ឌិតជាតិខ្មែរ ហើយជាការខូចដល់សេចក្តីសំខាន់ខាងផ្លូវនយោបាយផង ។

ផ្នែកបាលីខ្មែរ មិនមែនមានព្រួយកែក្កអំពីរឿងនេះតែម្នាក់ឯងទេ សូម្បីប្រទេសបារាំងសែស ដែលជាអាណាព្យាបាល ជាប់កិច្ចសន្យា ក្នុងការនាំផ្លូវ ព្រះពុទ្ធសាសនាប្រកែខ្មែរ ចូលក្នុងផ្លូវចំរើន ទំនងផ្លូវជាតិ ជ័យជំនឿក៏មានព្រួយកែក្កដូចគ្នាដែរ ។

ហេតុដូច្នេះហើយ បានជាក្នុងឆ្នាំ ១៩១៤ រាជការអាណាព្យាបាល បារាំងសែសបានព្រមព្រៀងជាមួយនឹងព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានបង្កើតសាលាបាលីនេះឡើង នៅប្រទេសកម្ពុជា ។ លុះអំណើះតមកបានកែប្រែបំប៉ាសាលាបាលីជាន់ខ្ពស់ ដែលបណ្តាលឲ្យមានកេរ្តិ៍ឈ្មោះល្បីល្បាញ នាំឲ្យពួកនិស្សិតស្រុកលាវ និងស្រុកកូស័ងស៊ីន តែចូលមករៀនជាច្រើន នៅសាលាបាលីជាន់ខ្ពស់របស់យើង ។

តាំងអំពីកាលកំណត់នោះមក ពួកអ្នកប្រាជ្ញបារាំងសែសចុងបូព៌ា ប្រទេសក្តី ពួកបណ្ឌិតជាតិខ្មែរក្តី ទាំងព្រះសង្ឃ ទាំងគ្រហស្ថ បានខំប្រឹងប្រែងពួកដៃគ្នាបង្កើតកិច្ចការស្នាដៃ ១ ដែលគួរឲ្យសរសើរហើយ ជាទីឥតូនៃប្រទេសពុទ្ធសាសនាដទៃៗ ។

ព្រះករុណាទាំងឡាយ សូមព្រះគុណគិតដល់ការបោះពុម្ពព្រះត្រៃ-បិដកជ័ទឡារ៏តនោះចុះ ។ អំពើនេះជាផលដ៏ជាក់ស្តែងរួបរួមគ្នា នៃសហការរបស់យើង ។ នេះហើយដែលជាផ្លែផ្កា នៃចំណោះបេះដូង

របស់ព្រះករុណាទាំងឡាយមែនពិត ប៉ុន្តែការត្រិះរិះពិចារណារបស់ព្រះករុណាអាចកកើតជារូបការទៀងបាន ដោយសារជំនួយខាងថ្វិកាដ៏ធំរបស់យើង ។

ខ្ញុំករុណា ទើបក្លាយមកធ្វើជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យក្រោយគេបង្អស់ ហើយបានធ្វើការក្នុងពេលខ្លីផង ប៉ុន្តែខ្ញុំករុណាមានឱកាសល្អ បានស្គាល់ព្រះករុណាផង បានស្គាល់ដំណែលនៃវិទ្យាសាស្ត្ររបស់ព្រះករុណាផង ដែលជាវិទ្យាដ៏បរិសុទ្ធត្រាលត្រៃ ។

ខ្ញុំករុណាដឹងជាក់ថា បាក់ឯសែសបច្ចុប្បន្ននេះនឹងធ្វើការតទៅទៀតជាមួយនឹងព្រះករុណាទាំង ៣ អង្គ ដ្បិតព្រះករុណាធ្លាប់ធ្វើជាសិស្សលោកល័ប-ហ្វីណូត៍ ដែលជាបណ្ឌិតខាងភាសាបាលីក និងជាអ្នកផ្តួចខាងបាលីដ៏ល្បីល្បាញផលមកឥឡូវនេះ ព្រះករុណាបានទ្រទ្រង់សមណសក្តិដ៏ខ្ពង់ខ្ពស់ក្នុងគណៈសង្ឃពុទ្ធសាសនា ហើយធ្វើជាគ្រូអាចារ្យបង្រៀនសាលាបាលីជាន់ខ្ពស់នេះ ។ ហេតុដូច្នេះ បានជាខ្ញុំករុណាគ្មានញញើតទេ ត្រង់ការដែលខ្ញុំករុណាបានទទួលកិត្តិយសជាអ្នកប្រគល់សាលានេះជាកំណង់ព្រះហស្តរបស់ព្រះករុណា ។ ខ្ញុំករុណាជឿជាក់ថា ព្រះហស្តអស់នេះ ជាព្រះហស្តគួរគោរព ហើយប៉ិនប្រសប់ផង មុខជានឹងមិនបណ្តោយឲ្យរៀវរោយទៅឡើយ ។

ក្នុងការជ្រើសរើសយកសាលាបាក់ជាន់ខ្ពស់ ប្រគល់ចំពោះព្រះករុណានេះ ទុកដូចជាបង្ហាញទឹកចិត្តដំបូង នៃឆន្ទៈរបស់បារាំងសែសដែលប្រគល់ឲ្យយ៉ាងស្រួលកន់ សមដល់ការប្រកាសឯករាជ្យដ៏ឧឡារិក ដែលលោកកុម៉ីស្សែរជីឡារេតុយតូក បានបំពេញលក្ខណៈសារ ប្រកបដោយគ្រឿងសញ្ញាដ៏ខ្ពង់ខ្ពស់មកហើយ ។ ការប្រគល់លើកជំនូននេះ ប្រែសេចក្ដីថា ចំណែកមួយនៃប្រទេសបារាំងសែស ស្មោះត្រង់នឹងកិច្ចសន្យារបស់ខ្លួន ឥតអល់ឯន នឹងការឲ្យសេរីភាពខាងការងារ នឹងខាងផ្លូវគំនិត ចំពោះអ្នកតស៊ូសមគួរនឹងទទួលបាន, មួយចំណែកទៀតដើម្បីបញ្ជាក់ឲ្យឃើញភស្តុតាងថា សម្ពន្ធភាពរវាងបារាំង-ខ្មែរ ចូលទៅក្នុងថ្នាក់ថ្មីមួយ ជាថ្នាក់ប្រកបដោយចំណងខាងផ្លូវគំនិតនឹងខាងផ្លូវចិត្ត ដែលបណ្ដាលឲ្យបានចំរើនដោយភាតរភាពដ៏បរិបូណ៌ ។

ហើយការពួតដៃគ្នាខាងផ្លូវចេតនារម្មណ៍នឹងផ្លូវសតិបញ្ញារវាងជាតិយើងទាំងពីរនេះ នឹងកើតជា "របៀបជីវភាពថ្មី" ឡើង ក្នុងសករាជថ្មីនៃពង្សាវតាររបស់ប្រទេសកម្ពុជា ដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់មានព្រះរាជឧត្តមមកហើយ ហើយត្រូវនឹងពេលសករាជថ្មីដូចគ្នាសម្រាប់ពង្សាវតាររបស់ប្រទេសបារាំងសែស ដែលត្រូវរួបរួមជាមួយនឹងប្រទេសកម្ពុជា ញែកចំបែកចេញពីគ្នាពុំបានឡើយ តាំងពីឥឡូវនេះតទៅ ។

ប្រៀង់ស្វារ-ម៉ារ៉ូង

## សុភាសិត អ្នកប្រាជ្ញក្រោក។

# លោក រ៉ាយ-ប៊ុក ប្រែ, ឃុន-សុវត្ថិវេទ័យ្យ-អ៊ុន ពិនិត្យកែ

---

១ - ឲ្យឯងទុកចិត្តខ្លួនឯង, បើស្គាល់ខ្លួនក្នុងខ្លួនឯង មុនជាឯង នឹងស្គាល់ត្រៃភពលោក នឹងអរិយបុគ្គល ។

បុរិមសិលាចារឹក នៅព្រះវិហារស្រុកដេលហ្វិស

«ត្រូវទុកចិត្តខ្លួន បើស្គាល់ប្រជួន ក្នុងខ្លួនអាត្មា នឹងស្គាល់លោកធាតុ ស្គាល់ជាតិសាសនា ស្គាល់លោកអរិយា ថ្លៃថ្លាដោយគុណ» ។

២ និទ្រា, និម្មិត, អប្បនាចិត្ត, ទាំង ៣ នេះ ជាទ្វារបើកចំហ សម្រាប់ដើរទៅដល់ភពខាងមុខ, ហើយជាឫសគល់នៃច្បាប់វិធីហាត់ចិត្ត នឹងក្បួនហោរាសាស្ត្រ ។

ពីថាគ័រ

«និទ្រា និម្មិត អប្បនាចិត្ត ប្រាជ្ញគួរពិនិត្យហាត់តាមការ ទើបនឹងយល់ភពភូមិលោក ក្បួនច្បាប់ហោរាការហាត់ចិត្ត» ។

៣ សេចក្ដីចំរើនជាច្បាប់ជីវសត្វ, លេខជាច្បាប់ភពលោក, មួយជាច្បាប់ព្រះ ។

ពីថាគ័រ

«ការចំរើនដោយទ្រព្យសម្បត្តិ ម្យ៉ាងចំរើនសុខាភតមោះមៃ ទុកជាច្បាប់សព្វសត្វរស់រាល់ថ្ងៃ វិនិច្ឆ័យលៃលកយកជាគ្រូ ។ លេខសំខ្យា

លេខជាសម្រាប់ពិប ទុកជាប្រាប់កតលោកគ្រាន់តែគន្លូវ អន្តរគត ប្រាជ្ញដែលជាសត្រូវ លើកឯកោតមួយជាត្រៃយប្រាប់» ។

៤ - កុំបណ្តោយចិត្តឲ្យកើតទុក្ខដោយអំណាចជនមិត្ត មុននឹងពិចារណាបំផុត ទូវកិច្ចការក្នុង១ថ្ងៃ ខ្ញុំធ្វើខុសត្រង់ណាខ្លះ ខ្ញុំបានធ្វើអ្វីខ្លះ ខ្ញុំមិនបានបំពេញកិច្ចការដោយសុចរិតអ្វីខ្លះ, ត្រូវគិតរកខុសត្រូវផ្លូវកាយ-វាចា-ចិត្ត តាំងពីព្រឹករាមដាន់តាមរៈណា:' បើឃើញខុសឲ្យបញ្ចោសខ្លួនឯង បើឯងធ្វើត្រូវឲ្យញុំាងចិត្តរីករាយតាមលំដាប់ ។

សុវណ្ណកាព្យឃ្លោង ពីបាក្យ ៤០-៤៤

«កុំឲ្យជនមិត្ត មករំលោភចិត្តអាត្មា ត្រូវគិតសព្វកិច្ចការ អតីតា ពាំងបច្ចុប្បន្ន ។ មួយថ្ងៃអញធ្វើអ្វី ខុសត្រូវក្តីល្អតាមជាន់ ឬពុំណាត្រូវគុណ សោភ័ណ ជនជាតំរូវ ត្រូវគុណខ្លួន ។ ត្រូវផ្ចង់សេចក្តីខ្ជាប់ កុំប្រាពេ ធ្វើមធ្វើផុត បើការល្អចាំមួន ត្រូវថែថ្នមគាប់តែទ្រូយ ។ ផ្លូវកាយវាចាចិត្ត ត្រូវចាំតាមភាគត់ពល់ថ្ងៃ ផ្សៀងផ្ទឹមតាមវិន័យ ទើបប្រពៃពេញក្នុងប្រុស» ។

៥ - ក្បួនច្បាប់ជាបឋម គឺឯងត្រូវគោរពកោតខ្លាចខ្លួនឯង ។

សុវណ្ណកាព្យឃ្លោង ពីបាក្យ — ៩២

«ក្បួនច្បាប់ជាបឋម យ៉ាងឧត្តមគឺខ្លួនឯង គោរពខ្លាចរអារក្រែង នឹងខ្លួនឯងបញ្ចោសខ្លួន» ។

៦ - សេចក្តីប្រាថ្នាយ៉ាងវិសេស សេចក្តីប្រាថ្នាជាចំណុចចិត្ត សេចក្តីប្រាថ្នារបស់សត្វ ដែលទំព្រើនប្រែងពសាងជាតិ គឺប្រាថ្នាចង់

ទៅដល់ទីមួយ ដែលនាំឲ្យជ្រះថ្លាក្នុងសន្តានយ៉ាងក្រៃលែង ដោយបាន យល់ច្បាស់ក្នុងចិត្ត នូវធម៌ដ៏បរិសុទ្ធស្អាតផុតពីសង្ស័យនិងគិត ។

ប៊ូតាំង (បុប្ផា-វិសដ្ឋិតា, ១.៦)

«ប្រាជ្ញានៃសត្វលោក គឺចង់លោតលេងផុត ចាកក្បួនដែលនេះ ផុត សន្តានសុទ្ធតែកុំទុក ។ ស្អប់ខ្ពើមនរបោកបាច ជាសភាពមិន មែនសុខ ស្រឡាញ់ធម៌ប្រមុខ នៃស្ថានសុខគឺនិព្វាន» ។

៧- ក្អែនសំឡឹងនូវនិមិត្តដែលពេញចិត្ត ហើយខំប្រឹងប្រែងធ្វើ ការ, បុណ្យជារូបចម្លាក់ដ៏វិចិត្រ នៃប្រតិមាសុចរិតជាជាង ឈ្មោះ ហ្វីឌីយ៉ាស, ជាគ្រូដែលធ្វើ គឺចិត្តដ៏បរិសុទ្ធ, គំរូដែលធ្វើការ គឺព្រះ ។

ប្លាតុង

«បុគ្គលត្រូវសំឡឹង ទៅឲ្យនឹងត្រង់និមិត្ត ដែលខ្លួនសព្វគាប់ចិត្ត ដៃពិនិត្យប្រឹងធ្វើការ ។ បុណ្យក៏ត្រូវគាប់ហ្សា ជារចនារូបបុះស្នាម, សុចរិតដែលដិតជាប់ ខុតជាជាងដែលចាក់ចែង ។ គំរូដែលខំធ្វើ ដោយគំពើនៃខ្លួនឯង ចាក់ជាចិត្តស្អាតពេញ, គំរូនៃនខុតជាព្រះ» ។

៨- មិនត្រូវត្រាប់ជាងសិល្បករ ត្រូវធ្វើតាមធម្មជាតិ ។

លី ស៊ិប្ប

«ធម្មជាតិគឺសង្ខារតាក់តែង វិចិត្រខ្លួនឯងល្អសោភ័ណ តាម ថ្នាក់តាមបែបតាមពួកជាន់ ក្លយ៉ាងថ្កានផ្កាឈើព្រៃ ។ ធម្មជាតិទាំង

នេះទុកជាគ្រូ នៃជាងគំនូរឬប្អូនការដៃ ឬនេះឈ្មោះគ្រាប់ធម្មជាតប្រែពៃ កុំគ្រាប់ ស្នាដៃសិល្បករ ។

| | |
|---|---|
| ធម្មជាត | ធ្វើតាម |
| ពោលភ្លាម | កុំជឿ |
| ជាងធ្វើ | កុំគ្រាប់ |
| ទម្លាប់ | ជាធំ |
| ប្រឹងខំ | មិនហួសវិស័យ |
| ជាតិសុរិយ៍ | ចុត្តបុរេ ។ |

៩ - ជួយធម្មជាតហើយធ្វើការជាមួយវា, ធម្មជាតនោះមុខជា សំគាល់ឯងថាជាអ្នកផ្តើមហេតុ ហើយវានឹងស្តាប់បង្គាប់ឯង ។

ពីតាកួរ

«ធម្មជាតបង្ហាញវិជ្ជាគ្រប់ ចំពោះជនប្រាជ្ញពុទ្ធិការនោះ ដោយយកចិត្តទុកដាក់ ធម្មជាតិមុខជាស្តាប់ទុកផង ។ តែជាកិច្ចការពិតតម្ម គឺងប្រាជ្ញដឹកនាំអ្នកទោល ឲ្យបេះវិសេសវិសេសសល់ខ្លាត ដោយប្រើនសង្ខាតមិនខ្វីខ្ញា» ។

១០- ត្រូវអ្នកគ្រាប់ពូកជនដែលធ្វើឲ្យគេពហានដំណើរលឿនទៅមុខ ហើយជាអ្នកនៃកៃប្រែគេឲ្យបានឡើងកាន់សេចក្តីចំរើន ។

សូរ្យអាសគ្រ

"គតិប្រទេសជាតិសាសនា បំរើនលឿនជាដរាបតែ ដោយសារ ជនណាចំប្រើនវៃ្ឆ សុំបុជ្ជនវៃមិនខ្លាចស្លាប់ ៖ ជននោះគួរជាអ្នករួមជាតិ ប្រុសប្រាណខ្ញីឃ្លាតយ៉ាងតម្រាប់ ទើបគតនៃខ្លួនមិនអន់អាប់ គួរុងរឿង តាប់ជាប់វែងឆ្ងាយ!. ។

១១ - គុណខណៈដែលចំពុងសូត្ររៀនហាត់ស្វាធ្យាយ ខ្លួនខ្ញុំកាន់តែចាស់ វិជ្ជាខ្ញុំកាន់តែចំរើនឡើង ។

សូលង់

"វិជ្ជាទីនវ័យនៃមនុស្ស មិនគួរឲ្យខុសជំនាន់គ្នា វ័យៈប្រែប្រួល បំរើនវិជ្ជា តាំងពីរស៊ក្មេងរៀបប្រពៃ ។ ជនណា ខំព្យាយាមរៀនមុន បន្ទាប់ វ័យខ្លួនកែសម្ញៃ ជននោះលោកចាត់ជាប្រុសថៃ្ល ច្រើនគេហៅឈ្មោះក្រៃក្រុង លោកនេះ ។

១២ - មនោមយិទ្ធិ (រិទ្ធិសម្រេចអំពីចិត្ត) នៅជិតនិស្ស័យកំស្ទា ហើយជាអ្នកណែនាំនិស្ស័យកំស្ទាឲ្យមានបុព្វានុភាព ។

ពីថាកូរ

« មនោមយិទ្ធិនឹងកំស្ទា ជាមិត្តប្រការនេះនៃបពិត្រ តែងជួយគ្នាស្រោច ដែលប្រពិត ដើម្បីគិតធ្វើគ្រឿឲ្យសម្រេច » ។

១៣ យើងត្រូវតែព្យាបកាយឲ្យបានសុខសប្បាយ ត្រូវសម្តោស គុនកត្តាហារ ត្រូវហាត់ប្រាណដើម្បីឲ្យធាតុប្រព្រឹត្តទៅស្រួល - កិច្ចដែល

ប្រសើរបំផុត គឺធ្វើអត្តភាពមិនឲ្យទៅជាទន់ល្មន់ល្អាស ។ ហេតុនេះ ត្រូវឯងទម្លាប់ខ្លួនឲ្យរូបកាយស្អាត ឲ្យមានកម្លាំងខ្លាំង ។

ពិតាគូរ

« ហៃកូនសិស្សបិតា ត្រូវរក្សាខ្លួនឲ្យសុខ កុំធ្វើអំពើទុក្ខ អំពើធ្ងន់ធ្ងរនានា ៗ ចូរកូនសិស្សសន្តោស ត្រេកចំពោះភក្តាហារ ចំណីណាដែលជាមិនមានទោសដល់រូបា ។ ចូរកូនធានហាត់ប្រាណ តាមលំនាំនៃល្បែងប្រាជ្ញា ឲ្យធាតុជាសុខា តាំងកាយាមាំមួន » ។

១៦ - មនុស្សអ្នកបណ្ដោយចិត្តឲ្យពាយមាយ តែងច្បាំងនឹងសេចក្ដីទុក្ខរហូត ១ ជីវិត ។

ហេសិអូត

« អ្នកតាំងចិត្តមាំធ្វើការសុខ, អ្នកពាយមាយទុក្ខគ្រប់វេលា ធ្វើអ្វីមិនប្រាកដចិត្តា ជាអ្នកវេទនាមួយជីវិត » ។

១៧ - កុំឲ្យធ្វើតាមពាក្យសំដីទទឹងកិច្ចការរបស់អ្នកដទៃ ដោយឥតពិចារណា រោលហើយធ្វើចំពោះតែការណា ដែលបានគិតគូរទៅឃើញថាគាប់ធ្វើបាន ។

ពិថាគូរ

« ដកគួរប្រុងធ្វើបរិនគាប់ កុំឲ្យជឿស្ដាប់អ្នកដទៃ បើធ្វើតាមគេត្រូវពិច័យ ឃើញថាប្រពៃសមធ្វើចុះ » ។

១៦ - បុព្វការីបុគ្គល មានចិត្តពប់ការស្រឡាញ់កតញ្ញូបុគ្គល ជាងកតញ្ញូបុគ្គលស្រឡាញ់ពប់ការបុព្វការីបុគ្គល ។

អារីស្តូត

« អ្នកធ្វើគុណមុន ចិត្តមិនចុះផង តែងរីកស្រស់ស្រាយ ពប់ការស្រឡាញ់ ពួកជនទាំងឡាយ ដែលបានសុខកាយ ដោយគុណឧបការៈ ។ អ្នកដឹងគុណតប ច្រើនមិនប្រាថ្នា ចង់យល់កគ្រា ញញើតខ្មាសគៀន មិនហ៊ានខ្ទា សំដែងគារវ អ្នកមានគុណឡើយ ។

១៧ - អ្នកណាលះបង់ទាំងអស់ អ្នកនោះនឹងបានទាំងអស់ ។

ប៊ូតាំង

« អ្នកណាលះតណ្ហាកិលេស ដែលតែងចាក់ស្រែះស្រាបសត្វនានា អ្នកនោះនឹងបានសំរេច ជាទីក្សេមក្សាន្តនិរភ័យ ។ បើជាផ្លូវលោកបាន ផល់ជន អ្នកមានចិត្តចង់តែងកតាក្រែ ប្រជុំដឹកជនមិនខ្លាចក្សយ បរាជ័យសុំវិល័យឲ្យជនជាតិ ។ ជននោះឈ្មោះថាលះទាំងអស់ នឹងបានរបស់ថ្លៃឥតឃ្លាត គឺគ្រាំឈ្មោះនាមល្អឮរយាត ដែលជនរមែងជាតិសូរ គោរព » ។

១៨ ជីវិតរស់នៅចុងជួបជាស្លាប់, តាមពិត រូបកាយយើងជាផ្ទះ ស្នាក់សពរបស់យើង ។

សូក្រាត

«សត្វទាំងឡាយ ដែលមានរូបកាយ កើតមកហើយ មិនមានសត្វណា រួចចាកមរណៈឡើយ ហេតុនេះអ្នកកើយ រស់ទុកដូចស្លាប់ ។ តាមពិតរូបកាយ សត្វនៅពិត ជាផ្ទះសាកសព ចេះគួរតែយើង ស្វែងរកគុណគាប់ ទុកកេរ្តិ៍ឲ្យជាប់ តពូជពង្សចៅ» ។

១៩- ករណីយកិច្ចគឺមនុស្សគ្រប់រូប ត្រូវតែបំពេញតាមឋានៈខ្លួន ។

ប៉ា-កុត

«អ្នកស្រែធ្វើស្រែ រដ្ឋមន្ត្រីត្រូវ រក្សាជនជាតិ ពាណិជទិញលក់ ពួកជាងទំឃាត ក្មេងៗសង្វាត រៀនវិជ្ជាសាស្ត្រ ។ សង្ឃក្នុងសាសនា ប្រឹងប្រែងសិក្ខា ពលការដ្ឋក្រស្ត ស្ដេចត្រូវប្រព្រឹត្ត ទសពិធធម៌ច្បាស់ បណ្ឌិតប្រាជ្ញឈ្លាស ចុះបំភ្លឺជន» ។

២០- បើធ្វើល្អហើយពួកគេនិន្ទាថាធ្វើអាក្រក់, នេះជាការប្រសើរ ។

អេពិកតែត

«ធ្វើល្អសោកណា សុចរិតគ្រប់គ្រាន់ ត្រឡប់បែរជា មានជនប្រុសស្រី ពោលស្តីនិន្ទា អ្នកប្រាជ្ញប្រាប់ថា កុំឲ្យអន់ចិត្ត ។ បាបបុណ្យមិនបាត់ ធ្វើហើយមិនខាត តែងតាមដោយពិត ឲ្យផលជាក់ស្ដែង ក្នុងត្រាណាពិត ដូចស្រមោលតិត អន្ទោលតាមប្រាណ ។

២១- ហេតុម្ដេចក៏ទៅទោមនស្សខឹងវត្ថុឥតវិញ្ញាណ ដែលមិនចេះខឹងនឹងយើង ។

អឺរីពីឌ (បែលេរូហ្វុន)

«ត្រូវទំហាត់ចិត្ត កុំឥតគំនិត ទំនងទំនិតស្ដុការ ដែលគ្មានវិញ្ញាណ មានតែរូបា បើទំនងលោកថា ជាមនុស្សប៉ប្រៃ ៗ មួយទៀតកុំទំនង ទំនងជន ពុំដឹង កិច្ចការប្រពៃ ទុកអ្នកនោះឯង ដូចជាឈើព្រៃ បើទំនងក្រោងវៃ នាំតែខូចធាតុ ៗ ជនណាប្រាំអត់ ខន្តីសង្កត់ រក្សាមារយាទ មិនទំនង ផ្តេសផ្តាស ពួកបណ្ឌិតជាតិ សរសើរជាអាទិ៍ ជាអ្នកជួនជួ» ។

២២ - បច្ចាមិត្រមានប្រយោជន៍ដល់យើងដែរ នឹកគាប់បង្ហាញ កំហុសរបស់ យើង ហើយពោលពាក្យពិត ។

ប្លុយតាក

«មនុស្សយើងមានខុសផុសមារយាទ អាក្រក់មិនស្អាតហាលចេញ បាន ដោយសារបច្ចាមិត្តរកពន ពុះពារបំពានហានថ្លែងទោស ។ ព្រោះគួរតាត់ថាបច្ចាមិត្រ មានប្រយោជន៍ពិតដល់យើងផ្ទោះ យើងកុំបី អាក់អន់ចំពោះ ត្រូវតែសរគ្រោះថាមានគុណ» ។

២៣ - សេចក្តីបរិសុទ្ធចំពោះចិត្ត សេចក្តីស្អាតចំពោះរូប ។

អេពិកតែត

«ជាតិមនុស្សត្រូវទុំផុសសំអាត ចិត្តឲ្យស្អាតបាតប្រាសមន្ទិល ចិត្តនេះ បើបណ្តោយឲ្យខិល អាចឲ្យរេចរិលតាមចៅខ្លួន ។ រូបកាយសព្វគ្រាយ តាំងស្រេច ក៏ត្រូវប្រិតប្រងទំថែជួន សំអាតផុសលាងឲ្យស្អាតមួនតាំង គ្រឿងតែងខ្លួនសំអាតផង ៗ សរស្អាតរូបប្រាណទាំងអម្ពរ ជាគុណបវរ ក្រែកខ្លួន ធ្វើកាយឲ្យសុខឲ្យហ្មត់ហ្មង ឲ្យល្អបព្រិមពេញចិន្តា» ។ (មានត)

# ទំនៀមធ្វើស្រែខ្មែរកម្ពុជាក្រោម

អាចារ្យ ទិញ-ប្រាជ្ញ អាចារ្យពុទ្ធសាសនបណ្ឌិត្យ នៃក្រយ៉ាង ក្លសាំងស៊ីន

(រង្វាន់លេខ ១)

---

អ្នកប្រទេសនេះតែងលុះខែដើមឆ្នាំ គឺខែពិសាខ កាលបើមានភ្លៀងធ្លាក់ម្តងពីរដង គឺចាប់តាំងផ្ដើមធ្វើស្រែ តែមុនពេលដែលចុះដៃធ្វើស្រែនោះជាទំនៀមរបស់ស្រុក គឺមានការឡើងអ្នកតាជាដំបូងសិន ។

## អំពីរបៀបឡើងអ្នកតា

តាមទំនៀមទម្លាប់អ្នកស្រុកនោះ តែដល់ដើមខែពិសាខអ្នកស្រុកតែងនាំគ្នាឡើងអ្នកតា ឯថ្ងៃដែលត្រូវឡើងអ្នកតានោះ គេយកដើមចេកមកកាត់ ១ ហោម ឬ ១ ចំអាម បំពង់ឲ្យស្រួច យកស្លឹកដូងមកដោតធ្វើជាជម មានគម្រោះសំពត់ធ្វើចំណាំងដាក់ពីលើជម អ្នកដែលចង់ឲ្យពូកែស័ក្តិសិទ្ធិមែន ក៏យកទៅចំពាក់លើរូបអ្នកតាតែម្តង . របៀបបែបនេះ មានគ្រប់ផ្ទះអ្នកដែលឡើងអ្នកតា ។

## អំពីគ្រឿងសំណែន

គ្រឿងសែនតាមទំនៀមនោះ គឺមានស្រា ជ្រូកស្ងោរខ្លះ ជ្រូកឆៅខ្លះ បើស្រុកណាខ្វះក្រមានតែក្បាលជ្រូកក៏បាន ទាស្ងោរ មាន់ស្ងោរ ចេក ក្រពង ដូងខ្ចី នំគ្រប់មុខ មាននំបញ្ចុក នំទៀន (នំអម) អន្សមជ្រូក

ផ្លែឈើ នំនំចាយម្ហូបផ្សេងៗ ប្រេង ម្សៅ ទឹកអប់ ទឹកដៃ ទៀន ធូប ប្រអប់ស្លា ហើយធ្វើសំពៅដើមចេក ១ ។

លុះដល់កំណត់ពេលវេលាទៅជួបជុំគ្នានៅផ្ទះអ្នកតានោះ រៀបគ្រឿងសំណែនស្រេចហើយ គេក៏អុជទៀនធូបបិទប្រអប់ស្លាតាក់សុប សែនបងផង គេហៅថាសែនព្រះពិស្ណុការក្មេង រួចលេងភ្លេងញាប់ ក៏តាំង អុជទៀនធូបម្លូនទៀតដាក់ទៅលើអ្នកតា ហើយចាក់ស្រាសែនបំពោរ អ្នកតាបងផង យកស្រាស្រោចលើអ្នកតានោះ ហើយគេក៏បាចផ្កាយ ម្ហូប ក្បាលជ្រូក ក្បាលមាន់ ទា នំនំគ្រប់មុខដាក់ក្នុងសំពៅសែន ញ ផងទៀត ហើយមានមនុស្សដែលចាស់ៗ ឲ្យពរជ័យ · សួស្តី · សុខ ហើយ ក៏ស្រែកហៅព្រមគ្នាឮកងឡើង តទៅនេះ គេនាំគ្នាជូនសំពៅទៅបាន ឆ្ងាយបន្តិចក៏ដាក់តាលក្នុងទឹកនោះទៅ នេះសន្មតថាជូនខ្មោចបិសាចចង្រៃ ឲ្យទៅផុតពីភូមិស្រុក រួចហើយគេនាំគ្នាបរិភោគបាយចំណីតាមកាល វេលាទៅ លំដាប់នោះគេក៏សូមចំណីដែលដាក់លើផមឬលើអ្នកតា នោះតែរៀងខ្លួន ដល់បានអម្បោះនោះមកយកទៅផ្ទះឲ្យកូនចៅ គេ ប្រើតាមត្រូវការ នេះជាទំនៀមរបស់ស្រុកពីបុរាណរៀងមក រឿងឡើង អ្នកតានេះ ខ្ញុំបាទបានដឹងឮ ឃើញដោយខ្លួនឯងផង ដោយបាន ឃើញគម្ពីររបស់លោកគ្រូអាចារ្យចាប ចាន់ តែងក្នុងក្រសួងពុទ្ធ-សាសនបណ្ឌិត្យនៃប្រចាំដែនកូសាំងស៊ីនផង ។

## អំពីជំនឿនៃការឡើងអ្នកតា

គឺគេឃើញថាតែបានធ្វើដូច្នេះហើយ អ្នកតាអាចប្រសិទ្ធពរឲ្យមនុស្សនិងសត្វទាំងអស់ឲ្យបានសេចក្ដីសុខចំរើន មិនតែប៉ុណ្ណោះគឺជឿជាក់ថា អ្នកតានោះអាចបណ្ដាលឲ្យទឹកភ្លៀងធ្លាក់មកត្រូវតាមរដូវកាល ដើម្បីងាយផលការធ្វើស្រែចំការ ។ ប៉ុន្តែការឡើងអ្នកតានេះតាំងពីព្រះពុទ្ធបណ្ណាល័យបានចម្រើនឡើងក្នុងកម្ពុជរដ្ឋ ហើយបានផ្សាយសាស្រ្ដធម៌ឲ្យផ្សាយសព្វទៅដល់ពេលណា ការគោរពបូជាអ្នកតាក៏ចាប់តែសាបសូន្យទៅបន្តិចម្ដងៗ រហូតមកដល់សព្វថ្ងៃនេះ ក៏នៅមានអ្នកបូជានៅខ្លះដែរ ប៉ុន្តែមានជាយ៉ាងចំនួនតិច ហើយអ្នកបូជានោះទៀតក៏បូជាដោយស្ងាត់ស្ងៀម ឬដោយគៀនគន់ មិនបានធ្វើទៅដោយពេញជំនឿដូចពេលមុនៗនោះឡើយ ។

បន្ទាប់អំពីការឡើងអ្នកតានេះ នឹងរៀបរាប់អំពីការធ្វើស្រែជាលំដាប់តទៅ ការធ្វើស្រែនេះ ត្រូវអាស្រ័យដោយប្រដាប់ស្រមាប់ធ្វើនោះជាច្រើន គឺប្រដាប់ស្រមាប់ធ្វើក្នុងរដូវភ្លៀង និងប្រដាប់ស្រមាប់ធ្វើក្នុងរដូវប្រាំងហើយ ។

ប្រដាប់ស្រមាប់ធ្វើក្នុងរដូវភ្លៀង ១- នង្គ័ល ២- រនាស់ ៣- ដុក ៤- ផាល ៥- ទំពក់ ៦- ត្រះត្រា ៧- ច្រៀង ៨- ដើងយាំ (តាំង) ៩- ដងឆក់ ១០- ឈើរែក ១១- ក្អាវដឹក ១២- ឈើកុង ១៣- ឈើប្រាន រវស់

ដែលប្រើដោយកំឡាំងក្របី គឺ នង្គ័លសម្រាប់ភ្ជួរដី រនាស់សម្រាប់ដាស់ឲ្យបែកដី និងរំលើងដើមស្មៅ ថ្ពកសម្រាប់កាយឲ្យបែកដីនិងបន្ទុំដើមស្មៅ ថ្ពកនេះគេយកឈើមួយទំហំ ២ តឹក បណ្តោយចំនួន ៣ ម៉ែត្រ គេយកមកលេខធ្វើជាស្ពឺ ១ ដូចជាផ្លែស្ពឺដូច្នោះមាន ៦ ស្ពឺ ហើយធ្វើជាពន្លួញ មូលនៅចុងទាំងសងខាង ហើយយកឈើ ១ សំប៉ែតចំនួន ១ តឹកកន្លះ កម្រាស់ចំនួន ៨ ហ៊ុន បណ្តោយប្រវែង ៥ តឹក ដាប់ត្រណាប់ពីរ ត្រណាប់ ១ ក្រោមដាប់ចូលសម្រាប់ស៊ិកពន្លួញថ្ពក ត្រណាប់លើដាប់ផ្ទង់សម្រាប់ស៊ិតពន្លួញផ្ទឹមថ្ពក ឈើនេះធ្វើជាត្រចៀកសងខាង ចំណែកឈើដែលធ្វើផ្ទឹមនោះត្រូវរកឈើឲ្យមាំបន្តិច ព្រោះនៅមានផង យកមកចោះភ្ជាប់និងផ្ទឹមនោះទៀត ហើយពេលដែលបរថ្ពកនោះទៅ ខ្លួនថ្ពកនោះរលាក់ភ្ជាន់ណាស់ បើផ្ទឹមមិនមាំក្រែងបាក់ ។

ប្រដាប់សម្រាប់ប្រើដោយកំឡាំងមនុស្ស ដាវសម្រាប់កាប់ឬក្រាយស្មៅ ចំពក់សម្រាប់ខ្វារស្មៅដែលឆាប់ឬក្រាយដាប់ហើយនោះ ចំពក់នេះពីដើមគេនិយមធ្វើដោយឈើ សព្វថ្ងៃគេច្រើនយកដែកមកពត់ធ្វើជាចំពក់វិញ ព្រោះដែកប្រើជាប់មាំល្អក្រាស់ ។

ជ្រោង

ជ្រោងនោះត្រូវមាន ២ គឺគេយកឈើមានដំបងពីរ ផងប្រវែង ១ ម៉ែត្រ ហើយគេសំរួចគល់ឲ្យស្រួច ដំបងនោះទុកវែងចំនួន ៤ តឹក

ពេលដកសំណាបគេយកទៅដោតខ្ទឹមចំនួន ១ ចំការមពីរ គឺល្មមតែយកសំណាបដែលដកហើយមកដាក់ពីលើកុំឲ្យជ្រុះ តែសម័យសព្វថ្ងៃគេប្រើនដកទឹងជើងម៉ាជំនួសប្រជានវិញ ។

## ជើងម៉ា

ជើងម៉ានេះ គេយកក្តារស្តើងទទឹងប្រហែល ៤ តឹក បណ្តោយប្រវែងប្រហែល ១ ម៉ែត្រ មានជើងដូចជើងម៉ាចម្លា ប៉ុន្តែជើងនោះខ្ពស់ចំនួន ១ ម៉ែត្រដូចប្រជានដែរ ពេលដកសំណាបគេដកហើយយកទៅលាងទឹក ហើយយកមកដាក់លើជើងម៉ា ហើយយកចំណងមកចងចុងសំណាបឲ្យគៀកនឹងជើងម៉ាដូចគ្នានឹងដកប្រជានដែរ របៀបដកសំណាបនឹងមានអធិប្បាយកទៅខាងមុខដោយច្បាស់លាស់ ។

## ដងធក់

ដងធក់នោះមានទ្រង់ទ្រាយដូចនេះ គឺគេយកឫស្សីទំហំប៉ុនកកួចដៃ ខ្លះពុះជាពីរក៏មាន ខ្លះទុកទាំងមូលក៏មាន ហើយសំរូបចុងជើងទាំងសងខាងឲ្យស្រួច ដងធក់នេះ គេសំពប់យកទៅរែកសំណាបដែលចងជាកណ្តាប់ហើយនោះ គឺយកចុងដែលសំរូបស្រួចនោះទៅដោតនឹងកណ្តាប់ម្ខាង ១ កណ្តាប់ ឬ ២ កណ្តាប់តាមកំលាំងដែលរែករួចយកទៅដាក់ក្នុងស្រែសម្រាប់ឲ្យគេស្ទូង ។

## ឈើរែក

ឈើរែកនេះគេយកឫស្សីចំនួនធំជាងកកួនដៃ បណ្ដោយប្រវែង ៣ ម៉ែត្រខ្វះ ឈើរែកនេះក៏សម្រាប់រែកសំណាបដូចឈើងងក់ដែរ ប៉ុន្តែ ឈើរែកនេះមានបង្គោលពីរសម្រាប់ចាក់ចុងដើមដង ឈើបង្គោលនោះគេច្រើនយកតាល់ឫស្សីណាដែលក្រាស់ៗមកធ្វើ គឺយកតាល់ឫស្សីវែងប្រវែង ១ ម៉ែត្រ ២ តឹក ខាងចុងជាពីរសំរួចល់ឲ្យស្រួច ហើយតែងក្បាលខ្វាងឲ្យមានជាប់តាមបន្ទិច ដើម្បីដាក់ឈើរែកពីលើកុំឲ្យធ្លាក់ ឈើរែកនេះរែកសំណាបបានច្រើនជាងងងក់ ពេលរែកគេយកបង្គោលទាំងពីរទៅដោតឲ្យឆ្ងាយពីគ្នា ស្មានមើលកុំឲ្យផុតចុងឈើរែក ហើយយកឈើរែកទៅដាក់គងពីលើ ហើយយកកណ្ដាប់សំណាបទៅចាក់ពីលើឈើរែក ៦-៨-១០-១២ តាមកំលាំងដែលរែករួច ឈើរែកនេះ បើសិនណាមិនមានបង្គោលទល់ទេ ដាក់ចុះលើដីនឹងដីគេម្តង ហើយយកសំណាបមកចាក់ ដល់បើនលើករែកលើកពុំរួចព្រោះធ្ងន់ពេក ហេតុហ្នឹងត្រូវមានបង្គោលទុកសំរាប់ទល់ ដល់ពេលរែកស្រាប់តែយកស្មាចូល ក៏រែកទៅតែម្តង ។

## ក្ដារដឹក

ក្ដារដឹកនេះមានច្រើនប្រភេទផ្សេងៗពីគ្នានេះ គឺគេយកឈើពោលចំនួន ៤ ហ៊ុន បន្ទាចំនួន ១ តឹក បណ្ដោយប្រវែង ១ ម៉ែត្រ ចាំង

ឬច្រាស់ ពុំមានឲ្យងើយឡើងបន្តិច សម្រាប់ធ្វើជាតីរដាក់សងខាង ហើយយកក្ដារបណ្ដោយចំនួន ៤ ម៉ែត្រ ៤ សន្ទឹម មកវាយជួបពីក្រោម ហើយវាយតាតាពីខាងក្នុងហៃតាំងពីមេរហូតដល់ចុងក្ដារ ដូចជាខ្នងទូក ដូច្នោះ ដើម្បីធ្វើការនោះឲ្យរាក់ បានជាឲ្យធ្វើមេនោះឲ្យងើយឡើងបន្តិច ប្រយោជន៍ដល់ពេលដឹកកុំឲ្យវាប់ចូលដី ក្ដារនេះ មានផងដែរ ប៉ុន្តែផង នោះមិនបានបោះឲ្យជាប់នឹងក្ដារ ដូចជាផាននង្គ័លឬរនាស់ដែលបោះ ឲ្យជាប់នឹងខ្នងនង្គ័ល ឬរនាស់នោះទេ ផងនេះគេយកឬស្សីឲ្យធំជាងកន្ទួន ដៃមកដាប់ខាងគល់ចំនួនបួនពីរជាប់ឲ្យជ្រុះ ហើយយកឈើ ១ សិតទទឹង ធ្វើជាតាយសម្រាប់ចុកថ្ពក់នឹងពូរ ដែលចងនឹងមេក្ដារដឹកទាំងសងខាង នោះ ផងក្ដារដឹកនេះ បានជាមិនបោះឲ្យជាប់ដូចជាផាននង្គ័ល ឬរនាស់ នោះ ព្រោះក្ដារដឹកនេះមានទម្ងន់ធ្ងន់ពេក បើសិនណាបោះឲ្យជាប់នឹង ក្ដារដឹកតែម្ដង ដល់ពេលដឹកក្របីគោវាផ្ទាត់ផ្ដួលទៅខាងនោះខាងនេះ ឬ ផុតភ្ជាំងកាបធ្វើឲ្យផងនោះបាក់ទៅៈជាយងាយ ក្ដារនេះពេលដឹកគេយក ក្របីឬគោមកទឹមដឹកដូចជាដឹករទេះ ។ វៀរតែគ្មានកង់ដូចរទេះ ក្ដារនេះ ដឹកបានតែស្រែណា ដែលមានទឹកខ្លះ បើស្រែនោះគ្មានទឹកសោះ ដឹកពុំរួចទេ ព្រោះក្ដារនេះធ្ងន់ ដឹក ១ ដើងបានចំនួន ១០០ ឬ ១២០ គណ្ដាប់តាមកំឡាំងក្របីគោខ្សោយខ្លាំង ។

## ឈើកុង

ឈើនេះសម្រាប់កាស់ដីស្រែដែលដុលឲ្យគេស្ទូង ឬព្រួត តាមទំនៀម ស្រុកនោះដុលគេស្ទូងព្រួត មិនមានកប់តាមស្រែទេ គឺកប់តាមគុន ១ គុនថ្ងៃប៉ុន្មានក៏ឲ្យតាមថ្ងៃនោះទៅ ឈើគុននេះយកឫស្សីប្រវែងហាលប៉ុន កំភួនដៃមកធ្វើ បណ្ដោយប្រវែង ២ ម៉ែត្រ ៨ តឹក រៀបកាស់គុននោះ ៣ ឈើហៅថា ១ កន្ទ្រង់ ៤ កន្ទ្រង់ហៅថា ១ គុន រួមគុន ១ គុនត្រូវជា ១២ ឈើ ។

## ឈើព្រាន

ឈើព្រាននេះមានទ្រង់ទ្រាយដូចត្រយូងចេក ប៉ុន្តែមានដងស្តួច ហើយមានក្បាលរីកធំបន្តិច គេដាប់ត្រណាប់ត្រង់កដែលស្តួចឲ្យឆ្ងាយទៅម្ខាង ហើយយកឈើ ១ សំប៉ែតធំជាង ១ ធ្នាប់ប្រវែង ១ ចំអាមមកសិតត្រង់ត្រណាប់នោះស្មៀតឲ្យរឹង ធ្វើជាដៃសម្រាប់កាន់គេលស្ទូងយកសំណាបមកចាក់ផ្ជាប់នឹងឈើព្រាននោះ ហើយលើកឈើព្រានចុកទៅក្នុងដីឲ្យមានប្រហោង ដៃ ១ ដែលទំនេរតែបេះសំណាប ដែលចាក់ផ្ជាប់នឹងឈើព្រាននោះស្ទូងទៅក្នុងប្រហោងនោះ បើស្រែនោះដីទន់មិនបាច់ប្រើឈើព្រានទេ ស្ទូងដៃតែម្តង គឺដៃ ១ ជីសំណាប ដៃ ១ បេះសំណាបដាំ ៗ មិនបាច់ប្រើឈើព្រានក៏បាន ។

## ក្រាំក្រា(១)

ក្រាំក្រានេះ មានទ្រង់ទ្រាយដូចរនាស់ដៃដែរ ប៉ុន្តែគ្រាន់តែវែងជាងរនាស់ដៃប៉ុណ្ណោះ គេយកឈើពន្លួន ៥ ហ៊ុន ២ ជ្រុង បណ្ដោយប្រវែង ២ ម៉ែត្រ ចេញប្រវែង ១ ចំអាម ហើយដាក់ឲ្យរង្វើលបន្តិច ហើយដាក់ដងពីរ រួចចងភ្ជាប់ចុងដងទាំងពីរជាប់គ្នា ប៉ុន្តែកន្លែងដងទាំងពីរធ្វើឲ្យល្មមចុះខ្លួនបាន ព្រោះពេលខ្លាស្ទៅគេប៉ូលខ្លួនទៅក្នុងរវាងដងនោះហើយគេដើរថយក្រោយដោយទម្ងន់ខ្លួន ទិនខ្លាដោយកំឡាំងដៃពុំរួចទេ ព្រោះខ្លាម្តងៗ ដោយស្ទៅជ្រៅណាស់ ។

## ប្រដាប់សម្រាប់ធ្វើស្រែក្នុងរដូវរំហើយ
## គ្រឿងប្រូតកាត់

១. ចង្កៀរ ១ នេះក៏មានរូបរាងដូចចង្កៀរនៅស្រុកខ្មែរយើងដែរ ។

២-. ក្រវៀម ១ នេះក៏មានផ្លែកោងដូចជាផ្លែកណ្ដៀវដែរ ប៉ុន្តែមានដងនោះត្រង់ខ្លីចំនួន ១ ហត្ថ ដូចនឹងកាំបិតសម្រាប់តែឈូនចុងប៉ុណ្ណោះ ។

(មានត)

---

១-. ក្រាំក្រា បើតាមលំដាប់ត្រូវគេអធិប្បាយក្នុងទី ៦ នៃប្រដាប់សម្រាប់ធ្វើស្រែ ទើបត្រូវ តែឥឡូវបានគេអធិប្បាយហួសមក ហេតុហ្នឹងទើបសរសេរជាខាងចុងវិញ ។

# កោកក្រុលកុមារ.

អ្នកចាកញ៉ាំព្រះឃ្លាំង ខង រៀបរៀង ហ្វូងនិពន្ធមន្ត្រី ញ៉ុក . ថែមរូបរួម
(តទីលេខ ១២ ឆ្នាំ ១៩៤៨)

---

បើអ្នកចង់មាន ទ្រព្យថាចង់បាន បុត្រាបុត្រី ប្រាជ្ញាយសស័ក្តិ ខ្ញុំប្រុសខ្ញុំស្រី សឹងបានដូចក្តី ប្រាថ្នាពុំខាន ។ ដ្បិតកេរ៌ជ័យ ជាមន្តលោក សម្រាប់ត្រៃត្រាន្ត ទ្រង់ព្រះមេត្តា ករុណាប្រោសប្រាណ ចង់ឲ្យទៅមាន បុត្រាបុត្រី ។ អាមាត្យបង្គំ ថ្វៃព្រះបណ្តាំ ព្រះបាទចក្រី ស្រែបរើបសែនស្តា នោះបរពូលខ្ញី ដាក់នៅវាសី ដំណេកនិទ្រា ។ អាមាត្យទាំងនោះ លុតលាចាកចុះ ចេញបរលីលា វិលវិលទៅដល់ មណ្ឌលត្រៃត្រា ទើបទូលដោយមានា ដំណើរសព្វគ្រប់ ។ ឯព្រះភោគី ខ្ញុំនាងនារី លុះល្បាចព្រលប់ បរិភោគភោជន៍ព័ស្តុ អាហារស្ងល់ស្ងប់ លង់លុះយូរយប់ បរទូលនិទ្រា ។ ហេតុកម្មមកដល់ នោះនាងនិមិល ខ្លឹងគន្ធពុទ្ធា ឲ្យជាប្រែហែល ភ្លេភ្លេសចិន្តា ពុំពិចារណា ពិនិត្យពិស្តារ ។ អ្នកនឹងនាងនាថ ពុំដែលព្រាត់ឃ្លាត គេស្រមក្សាន្តសាទរ ត្រេកអរយូរខែ ស្នេះស្នេហ៍ស្រែស្នេះសារ ត្រៀបវរ សំណេះបរបោះ ។ ចាំខ្ញុំជំរាប ឲ្យអស់ម្ចាស់ជ្រាប ដ្បិតព្រះឥន្ទ្រា ស្តេចដាក់ត្រណម បន្តមផ្តាំថា កុំឲ្យភោគ្កា ស៊ីគល់ក្តាំងឡាយ ។ ស៊ីតមាន់ស៊ីតទា បើអ្នកភោគ្កា កើតក្តៅក្រហាយ អស់អន្តអញខ្ញុំ ពិតពុំសប្បាយ ទឹងទប់ទល់កាយ និត្យនៅពុំបាន ។

ខ្ញុំរត់វិលទៅ នគរលំនៅ បិតាក្សត្រក្សត្ត ទូលព្រះមាតា ថ្លៃថ្លាប្រដាន ប្រាកដពុំខាន ដូចពាក្យខ្ញុំថា ។ បើអ្នកបេះគម ក្សត្រណោម ពិតពុំកោត្ដា អស់ទាំងស៊ុតស្ដូ ទៀនទាត់សក្យា បានទៅផងគ្នា ល្លុះអស់ជីវ៉ ។ ឯអង្គអមច្ចា ដែលតូនទៅនា កុងស្ដួរកេរ៍ សឹងមគបាំ ស្ដាប់ នាងប្រាប់ស្វាមី បានស្ដាប់សំដី សំដែងជាក់ច្បាស់ ។ លុះអរុ-ណោទ័យ សូរ្យាថ្លាថ្លៃ រឿងរះហោស ពីទិសបូព៌ា ស្ដេចមានតម្រាស់ ព្រះបន្ទូលត្រាស់ ប្រើអង្គអមច្ចា ។ ទៅសែងកេរ៍ ដ៏យបេញអំពី ផ្ទះតង្សព្ទា យកមកដាក់ដល់ មណ្ឌលក្សត្រា រះយកអមច្ចា បេញពាកកេរ៍ ។ ស្ដេចដណ្ដឹងថា អាមាត្យអើយអា បានព្រាក្យពី កោតកុល-កុមារ បរបាថាគ្នី នាងតើស្រីជ និយាយថាម្ដេច ។ អាមាត្យទូនអង្គ លុតលើកកន្ទុំ ប្រណម្យទូលស្ដេច តាមដោយឲ្យនដឹង ដំណាំងពាក្យពេចន៍ ត្រណាមការកិច្ច នាងប្រាប់ស្វាមី ។ ស្ដេចស្ដាប់ទំនូល អាមាត្យក្រាបទូល ជ្រាបអស់សេចក្ដី ទ្រង់ព្រះចិន្ដា គិតថាអំពី មុនមកក្រក្រី គិតទុច្ចាយ-ពល ។ ប្រើនដងប្រើនគ្រា យកប្រពន្ធរ៉ា ពុំបានសោកសល់ រាមានតេជះ តបះវិរិយពល បេះកិច្ចការពល សល្សុសាស្ដ្រធាប់ធុក ។ បេះនូវគិតទៀត ធ្វើពលវ៉ែងទៀត ឲ្យបានមានរត់ ទៅនគរនាយ ឲ្យឆ្ងាយប្រាកដ ឲ្យប្តីកំសត់ នៅតែម្នាក់ឯង ។ ហេតុស្ដេចអនុពាល គំនិតស្រើបស្រាល ស្មាតើរង្គង ពុំខ្វាចកម្មពៀរ ពាំទៀតអង្គឯង

ពុំគិតពុំគ្រែង ភ័យបតុកប៉ាំយ ។ ទើបស្តេចប្រញាប់ ទ្រង់ព្រះបន្ទាប់
ទៅអស់ចៅហ្វាយ ឃុំនគោជនសាល័ ពិសេសទាំងឡាយ ឲ្យរៀប
ស្រាបាយ ពិស្ទុភោជនា ។ អាហារចំណាប បន្ថែមផលព ស៊ីនស៊ុតមាន់
ទា ប្រឡាក់លាយខ្សំ ប្រឡំផងគ្នា ខ្ទះញាំក្តា លាយស៊ីនស៊ុតសត្វ ។
រៀបរូបស្រេចហើយ ពិតពុំលន់ឡើយ ទើបព្រះមហាក្សត្រ ត្រាស់ប្រើ
អមាត្យ យាត្រាទៅចាត់ ហៅពោធិសត្វ ទូវអស់មន្ត្រី ។ ឲ្យមកចួបជុំ
លើកដំណើរ បរិភោគចំណី អមាត្យលុកលា ក្សត្រាធិបតី ទៅហៅ
សេនី សេនាបតុរង្គ ។ ហើយហួសព្រះទៅ ដល់ទីលំនៅ មណ្ឌល
ព្រះពន្ធ គន្ធសាស្ត្រ ថ្លែងថាព្រះអង្គ មហាក្សត្រទើសទ្រង់
កម្រាស់ឲ្យហៅ ។ ទើបអ្នកម៉ូរា ដើរតាមអាជ្ញា ត្រែបត្រង់សំដៅ
ឡើងលុះលើបាន ពិមានលំនៅ កេងរមៀតគស៊ៅ គ្រញូក្រាបនៅ ។
ចួបជុំមន្ត្រី សេនាបតី កដរង្សពង្សា គង់តាលដេរដាស ពេញ
ពាសក្រឡា តំណាលកដា រៀបរៀនកល់កយ ។ ស្តេចទតទៅ
យល់ ពោធិសត្វដល់ គន្ធយពីឆ្ងាយ ទើបស្តេចត្រាស់ប្រើ ទៅ
លើចៅហ្វាយ ឃុំនឲ្យលើកបាយ លើកអស់ចំណី ។ ភោជនអាហារ
ផ្សេងៗត្រគាល លៀងអស់មន្ត្រី យោធាពលពន្ធ បតុរង្គសេនី
ហើយហៅពោធិ សត្វសួស្តីសោភា ។ ថៃហៅគោតគុល កុមារខ៉មិល
បរបូលគោត្តា ភោជនអាហារ ត្រកាលពីសា ជាមួយខ្ទង់គា.

មាត្យមុខមន្ត្រី ។ ពោធិសត្វស្តាប់ ស្តេចត្រាស់បង្គាប់ ឲ្យអ្នកប្រុសជី អ្នកជំនិតជាមហា- ក្សត្រាធិបតី ធ្វើកលចំណី លាយនឹងស៊ុតសត្វ ។ អ្នកតំគងបបថា បើពុំភោគ្គា សមព្រះមហាក្សត្រ ស្តេចទ្រង់ព្រះក្រោធ ពិរោធខ្ញាល់ក្តាត់ ធ្វើទោសទាល់តាត់ ដល់ក្ស័យជន្មា ។ ទើបពោធិសត្វ មហាបុរសរត្ន អ្នកចូលភោគ្គា ចំណីអាហារ ភស្តុភោជន៍ផង ព្រម ព្រះទ័យា គិតដល់មហេសី ។ ក្រែងនាងកល្យាណ នឹងនៅពុំបាន ពុំសុខក្រើយ ក្រហាយក្រហល់ រត់ដល់ទៅទី ខនរជនទី ជនកពីកា ។

## បទព្រហ្មគីត

គាលនោះនាងក្សត្រី នាងនៅទីឋានត្រីហា ពុំសុខក្នុងអង្គា កើតជាក្តៅក្រហាយលន់ ។ នឹងទប់នឹងទល់ប្រាណ នៅពុំបានទើបស្រែកខ្ទរ រំពឹងរិះគិតគន់ ថាទូលព្រះរៀមស្វាមី ។ សមស្តេចឃុបកំលៅ ឲ្យមករកអ្នកទៅទី ឲ្យបរិភោគចំណី លាយនឹងស៊ុតមាន់ពុំបាន ។ ទើបប្អូននៅឯកាយ ក្តៅក្រហាយពន់ប្រមាណ ខំនឹងទ្រាំនៅពុំបាន ប្អូនរកទៅស្រុកប្អូនវិញ ។ ទុសមគិតប្រាណ ព្រះស្វាមីម៉ែត្រសំឡាញ់ សមសៅសោកអមេញ ឆ្ងាកឯងនឹងនែអ្នកបកាល័យ ។ ខ្ញុំប្អូនបានឃ្លាតឃ្លា ឥតខណៈណានៅសព្វថ្ងៃ ត្រាំនឹងត្រាំការស្រ័យ នៅគំជាព្រះរៀមវ័ន ។ នាងសៅនាងសោកសោះ នាងអាឡោះឥន្ទអ្នកល់ការ ជោរជល់នេត្រ សស្រាក់ សស្រោចស្រោចព្រះភក្ត្រា ។ ទើបនាងនាងស្រីថ្ងៃ ផ្តាំថា

ហៃសុខា សសុខសមសោភា ចូរប្រាយប្រាប់ព្រះស្វាមី ។ ថាអញ ទៅក្រោយ ពុំសប្បាយក្នុងឥន្ទ្រិយ ទៅគ្គាត់ជួបអត្ត នេះពេលណា អស់អគ្គា ។ សុខខេមើយចូរស្តាប់ ចូរប្រាយប្រាប់ស្វាមីថា អគ្គអញ នេះក្រាបលា ទៅទសព្រះជនក ។ ទីទាំងនៅពុំបាន ទៅក្នុងព្រាណពិត ពុំសុខ ឥឡូវនេះអញទុក កែចំណៀនក្បួនទាំងពីរ ។ កានគូអញនេះនៅ ឲ្យបមបៅជាស្វាមី ជីនៈជីមគាថៈសេចក្តី សមសែនសោយសោកណាស់ ៗ បើចិត្តអត់ស្រឡាញ់ ចង់តាមអញទៅឲ្យដល់ ខរហៅទមណ្ឌល ទី ព្រះរាជបិតា ។ នាងណែប្រាប់ទំរ៉ទំ ទៅអំពីទគក នេះទីដល់ ជលសា សមុទ្រមួយនានចម្ងាយ ។ ប្រមាណ ១០ យោជន៍ទោះ ទៅពីនោះទៀតឡូវឆ្ងាយ ២៥ យោជន៍ឆ្ងាយ ទើបដល់ស្រុកអញទិត្យ នៅ ។ នាងថ្លាំសុខា កូនពកអួលកង់ក្តៅ ប្រែបនាងយាត្រាទៅ តែឯកអង្គដោយទារា ។ ផ្កុកផ្អើលទទួលគិត អួលណាណិតអនាថា ដោយភេទព្រះធីតា តែថៃមួយដល់បុរី ។ នាងនាងចាប់ចូលដល់ លើ មណ្ឌលមន្ទីរ ចង្កំព្រះជនន ខ្ញុំជនកជក្យក្រោ ។ ពីរក្រែករ ខនខុច ជួបក្រសោបភើបថៃថា ហៃកូនស្ងួនពៅ កាលព្រះនេត្រ-ធិបតី ។ មកយាងស្ងួនព្រលឹង ទៅជាខ្ទីនឲ្យមានខប្តី ឥឡូវមានហេតុ អ្វី ក៏កូនស្ងួនវិលវិញ ។ ទើបនាងក្រាបទូលថា កាលនេត្រ យកខ្ញុំចេញ ហោះទៅដល់អរញ្ញ នាងស្រុកពាក្យណាស់ ។ ស្តេច

ដាក់ខ្ញុំក្នុងថង់ ស្បែកព្រះអង្គទុកខាងទី បន្ទាប់ក្នុងសេដ្ឋី ឈ្មោះ
គោតកុលកុមារ ។ ខ្ញាក់ឯងគតសាច់ញាតិ ទាំងសង្កាត់ផ្ទើបការ មាន
កែស្រុនខា មួយសស្រុកខិត្យនៅផង ។ ផ្ទៃនោះមានយល់ថង់ ព្រស
នង្គុំនល្ងរំពង បន្ទុំស័ក្តិអីងង ក្បែរទៅដល់ក្នុងសេដ្ឋី ។ ដើមកយល់ថង់
ស្បែក ល្អចំវែក្សកយកទៅខ្ញី ដាក់លើមណ្ឌលទី ខាងដំណេកដែល
និទ្រា ។ ខ្ញុំសោតនៅចំរើ រៀបសារពើគោជនា តាមដោយពាក្យ
ឥន្ទ្រា បានជាឆ្នូនៅនៃបទនិត្យ ។ នាងទូលពីមស្រុក តាមគោជកបន្ទុ
ទុច្ចរិត ទូលរមហាក្សត្រគន់គិត ទបាយកលកំប្រើនគ្រា ។ នាង
ទូលសព្វសេចក្តី ឲ្យសម្តេចព្រះបិតា មាតាថ្លៃសោភា ស្តេច
ជ្រួតជ្រាបសព្វសេចក្តី ។ ទើបក្សត្រទាំងពីរថា ទស្សនគ្នាពេញពិសី
ហេតុបុណ្យហេតុបារមី គុណសម្តេចព្រះឥន្ទ្រា ជៀនជួយដោះទុក្ខភ័យ
មានជោគជ័យឈ្នះក្សត្រា បានរួចស្លូនពំនា វិលវិញមកសុខសប្បាយ ។
ទើបនាងក្រាបលាទៅ ទីលំនៅនាងគោមឆាយ អស់សុំស្ម័គ្រអកយាយ
បើនសប្បាយចិត្តនិប់គ្នា ។ នាងនាជនៅទីងទុក្ខ ពិតពុំសុខក្នុងចិន្តា
គន់គិតទៅព្រះមហា បុរសរក្តជាស្វាមី ។ ខ្សឹកខ្សួលឯងអាក់ព្រួយ
ព្រះកន្ត្រក្សត្រី ពុំជួបឈលប្រកតី ស្បៀមស្ងួនស្ងួប់ព្រះកន្ត្រា ។

# បទកាកគតិ

នេះនឹងនៅនិ - ទានទៅពោធិ - សត្វសួស្តីសោភា ឈលព្រះព្រហ្-
ទត្ត មហាក្សត្រពាលា ហៅទៅកាក្កា គោជទំពីស្តុចំណី ។ លុះថ្ងៃ
រសៀល សូរ្យាវៀល ទើបព្រះពោធិ ក្រញូំក្រាបលុតលា ក្សត្រា-
ធិបតី វិលវិនមកទី លំនៅគាត្ថា ។ ទៀងលើមណ្ឌល មៀនមើលពុំយល់
ភ្នេកផ្ចិតា កាំងកិតសុតស្ងួន ផណ្ដឹងសុខា នាងដើរមោណា ក៏
បាត់ពុំយល់ ។ សុនខគ្នាស់ស្នើយ ថាឥឡូវម្ចាស់អើយ ក្សត្រិនមើល
ពុំសុខសប្បាយ ក្រហាយក្រហល់ ទឹងនៅពុំស្គល់ អន្ទះអន្ទែង រក
ទៅរកមក ជជែលជជែក ចំព្រះកន្ទ្រង ខន្តីះខ្សឹកខ្សួល អាក់អួល
ម្នាក់ឯង ក្សត្រីថ្វាថ្ងួន បណ្ដាំខ្ញុំទិ ។ ផ្សិតនាងក្រាបលា វិលវិនខគក
បុរីត្រមៀ នៃព្រះជនក នាងទុកព្រះទំ- រង់ក្នុតិក្ខម ចាំងចិតនេះនៅ ។
ឲ្យម្ចាស់រក្សា គានគូធិកា សោះសោកក្តាត់ក្តៅ បើម្ចាស់ចង់បាន រូប
ហាងលំនៅ ឲ្យម្ចាស់តាមទៅ ដល់ខគនោយ ។ នាងណៃមគ្គា ចិសចី
យាត្រា អំពីហានគាយ ឲ្យចូនសមុទ្រ កំណាត់បម្លាយ ដល់ខគនោយ
យោជន៍ ៣៤ ។ ពោធិសត្វស្តាប់ សុនខប្រាយប្រាប់ ដូចពាក្យនាង
ផ្តាំ សត្វត្រេចសោចត្រេច ពាក្យពេចន៍ថែទាំ ចិត្តចាប់ចង់ចាំ គាលីយ
ក្សត្រ ។ ចំព្រះឧន្ទ្រង ពិលាបថ្វាថ្ងួន ទព្រះប្អូនស្រី ម្តេចមក
ប្រែប្រាស និរាសចេញពី បង់បាត់ទៅវី ចូរហានឃ្លាតឃ្លា ។ ទប្អូន

បណ្តូល បណ្តាប់ព្រួយព្រួស សាប់ស្លុតហាពេញ បងស្ងានប្អូនទៅ
មាននៅព្រៃហោ ធ្លាប់នៅនឹងវាំង សាន្តសុខរាជ្យ ៗ ធ្លាប់នៅនឹងព្រា
ពុំដែលឃ្លាតឃ្លា ដល់មួយរាត្រី ធ្លាប់រៀបរាបហារ ពន្លកាផងចំណី
ទិព្វទេសពិសី ពិសារឿបនី ៗ ប្អូនប្អូនទៅ មាសមេឃ្លាតទៅ
ចិត្តរបន្ទន់ ទុកតែចំរើន បញ្ចូនហាក់ហាន ទាំងចំហៀងរាង បងវិលស្រណោះ ៗ
រំលឹកតែដល់ស្ងួន ពន្ធទឹកខ្លួន ស្រយុតស្រណោះ ស្រមោលប្រែ
ហាក់ដូចស្តុយស្រោះ បងវិលអាឡោះ អាល័យពេកពន់ ៗ ខ្លួនទន់ល្វាណ
ចិត្តបងតក់ស្លុត ជាប្អូនមានគុណ ទឹកនៅនេះចិត្ត ស្នេហាបុំផុតផ្អួន
លុះអស់ជីពជន្ម ជីវិតផងក្ដា ៗ ចូនជំរះជាប្រុស ព្រាត់ព្រលឹងមាស
សាប់សង្វាច ពុំបានដែលទៅ ទូរទៅឃ្លាតឃ្លា សមបាដបុក បុរីផងតើ ៗ
ព្រះពោធិសត្វ ទូញទ្រាញប្អូនរ័ត្ន សោកសោយយំខ្លី អនាថនាណាត
គន់គិតនេរ័ រត្នបុត្រស្រី ជ្រៃប្រាសព្រាត់ព្រាត់ ៗ សោះស្រែបន្ទោ
ទូកទេចព្រះពោធិ ធរណីស្រុក ចំនួនយាត្រា លីលាទៅថ្កាត់ តាមព្រះ
ប្អូនរ័ត្ន រាជធីតា ៗ លុះព្រឹកឡើងអួត រៀបបទុំផាក់ ទំពក្រូន
ព្រឹបហា យកតែទំព្រឹន បញ្ចូនថ្ងៃថា ទូរស្មុនធា ចរបេញពីផ្ទះ ៗ
ដល់ស្រុកដូនចាស់ មានសប្បុរសណាស់ ជាក្ដាយតមិព្រះ ពោធិបម
ទៅ ឡើងទៅលើផ្ទះ ទើបអ្នកសំពះ សួរមាតាបមិ ៗ អ្នកប្រាប់ពីបាន
ក្សត្រីកល្យាណ ទំង់ចោមលោមព័ណ៌ ប្រាប់ពីស្នេហបាប ត់ណាប

អធម្មិ និកធ្វើអស់កាថិ ខុប្បាយគលគិច្ច ៗ ជួនពាស់ស្ដែងស្ដាប់
ពោធិសត្វប្រាប់ សព្វគ្រប់សេចគ្រិច ដើមដើមសេចក្ដី អំពីហេតុស្ដេច
ឈបតិតគលគិច្ច ខឹងឈ្មួកវិយា ៗ ហើយជួនពាស់ឃាត់ ព្រះពោធិ-
សត្វ ឲ្យបរិភោគ្គា ភោជន៍ពស្ដុបំណាំ គ្រឿងពិសា ឃាត់ឲ្យនិទ្រា
នៅមួយរាត្រី ៗ លុះព្រឹកព្រានព្រះ សួស្ដីសាងរឿងរះ ពីបូពិទិសទី
ហើយក្មួចក្រាបលា យាត្រាៈចេញខ្ចី ឆ្ពោះតាមទិសទី ផ្លូវដែលនាងផ្តាំ ៗ
ហើយក៏លចូលព្រៃ ត្រែមាចាះពតព្រៃ ឥតអ្នកណេះនាំ មានតែក្តីជឹង
ដំណឹងជាកំពាំ ពាក្យដែលនាងផ្តាំ នាំអ្នកយាត្រា ៗ ចូលក្នុងព្រឹក្សព្រៃ
ស្រោងស្រោងត្រៃឈើ ត្រឈើងសាខា មានដើមស្វាយស្វាគ លាំង-
សាខ្នុទ្យា លុងលុតសេដា ដូងដងខ្ទើព ៗ សាច់សរីមោះខមៀន
មង្ឃុតធូរេន គ្រៀញសំពារ ឥន្ទ្រីក្រៀលក្រុង ស្ពឺស្ពង់សត្វារ
ការប្រសែអ្វក - ណាឈស្ងួលស្វាយ ៗ ក្ដាំពួកាំពា ក្តាំពាក់ត្រឹស្នា
ចន្ទន៍តាដកពាយ ជតពត្ជម្ទឹង ត្រយឹងលោយ លើសល្ហុកយ ល្វើរើត
ធាំធា ៗ សណ្ដាសណ្ដាន់ សណ្ដែក្រអូន គ្រញូកេង ពិកុលពេកាំង
ពោតលាំងអំពា អំពិលទន្ទា ទន្លាប់ផ្អេផ្អុល ៗ ព្រីងព្រួសក្រវា
ធម្បាសបុស្ទី បង្គាដើមផ្កុល អង្កាញ់មាក់ប៉ែន គួលេនតណ្តូរ
តណ្ដុកត្រស់ល ត្រសិតក្ដាគគួ ៗ ស្រឡូស្រលៅ ស្រឡែតឈើ
ទៅ ឈើខ្ញុំខ្មួច ខ្ទៃងត្រៀង ទំពូងសង្ឃួប សង្ឃ៉ះពាន

ពួច ពកពៃពីងពង់ ។ ទាក់ដាកទាត់ប្រើង ទាក់ប្រាំងរំផេង
រំជួលព្រះព្រៃ ព្រះព្រាយផកកៃ យ៉ាយ៉ៃយូរធូរខ្វល់ យ៉ៃយ៉ៃខ្វល់គង់
ឥតរន្ធត់ ។ សំពេងសំរក សំរេងស្រឡក ស្រឡាក់សង្វារ សង្វា
ថ្កាលមាន លំពាន់លំពារ លំពោះដើមដក- ងងក់ក្លក់ក្លូ ។ ចង្វែង
ចង្វា ចង្វៀជង្វា បុសពេងស្រមូវ សមសមួល ពពួលខ្វាខ្វៀវ
យានយុត្តាថ្វើ ផ្គាក់ព្រៀលព្រាបព្រៀង ។ ស្រងាក្តាមក្តុល ពុព្រា
ព្រមុល ព្រមូងផ្តោះផ្តៀង ស្ទៀស្ទៀវស្ទៃស្នាច់ ពោលព្រោះស្រៀក
រលួសពព្រៀក កព្រាងពោងបាយ ។ ម៉ៃបងថ្ងៃថ្ង សាងសោម
លាំងដៃ ព្រំព្រះកំបាយ កំបាត់ស្តូស្តៅ ពិលពៅសណ្តាយ ក្រពោះ
ក្របក្រាយ ប្រើសប្រយៅផៃជ្រៃ ។ ពេលផងប្រេងពណ៌ ដុះដោយ
ដូរដរ ជ្រួតៗទាំង ផ្លូវត្រាស់ត្រាល ទ្រាលក្រាសព្រៃ ដេរដាស
ដោយព្រៃ ចូរគមអង្គ ។ ខ្ទះខ្ទិះខ្ទុំ ខ្ទះទេបក្រពុំ រំកពេយបុប្ផា
ពិដោរល្អល្អប់ សាយសព្វទិសា ខ្ទះផ្ទះផលា ដោកផ្កាផ្កាដី ។
ព្រះពន្លឺពុទ្ធ យល់យល់ផលា ទឹកដល់ក្យប្រើ ចាំស្ងួចស្ងួន ខ្ទុំខ្ទួនពីសី
ឃ្លាតនៅទូទី គំបងហ៊ានឆ្ងាយ ។ ទាំងនៅនេះណា ទីងឃើញផលា បរិភោគ
សប្បាយ ពីរនាក់ទាំងស្ងួន ខ្ទុំខ្ទួនពណ្ណរាយ ដើរលេងនិយាយ
ក្រសាលក្សេមក្សាន្ត ។ ស្ទើរប្អូនឃ្លាត បងខំសង្ខាត ប្រែបតាមដោយ
ដាន យល់ផលពីសី ទីងទីពុំបាន ផ្លែឃ្មុំពុំឃ្លាន មិនចង់ភោគា ។

(មានត)

# សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា ឡូ - កន តំណាងរាស្ត្រ

(តមក)

### វគ្គទី ៣

តាំងពីហូជិនទទួលសំបុត្រពីតាំងតុះ ហើយបំរុងទុកមិនឲ្យខន្ទី ១០ នាក់ដឹងសេចក្ដី ដរាបដល់លីយូដាក់ថ្នាំពុលលាយនឹងស្រា យកទៅថ្វាយព្រះនាងហូហោនិងហុងនូពៀន ដែលត្រូវរាជសម្បត្តិឲ្យទ្រង់សោយដោយបង្ខំ ។

---

ឯហូជិនដឹងក្នុងសេចក្ដីសំបុត្រតាំងតុះដូច្នោះ ក៏បំរុងប្រាំងមិនឲ្យខន្ទី ១០ នាក់ដឹងសេចក្ដី ទើបបង្គាប់ឲ្យហៅនាហ្មឺនមុខមន្ត្រីទាំងពួងមកប្រឹក្សាថា យើងនឹងឲ្យតាំងតុះចូលមកក្នុងក្រុងតើស្រួលមិនស្រួលដូចម្ដេច ? តេះថាយ ឆ្លើយថា តាំងតុះនោះចិត្តថ្វើមដូចជាសត្វខ្លា បើនឹងឲ្យចូលមកក្នុងក្រុងគង់នឹងកើតអន្តរាយដល់មនុស្សទាំងពួង ។ ហូជិនតបថា អ្នកនេះនឹងគិតការធំឲ្យជាមួយនឹងយើងមិនបានទេ ត្រាន់តែឮដំណឹង មិនទាន់ឃើញខ្លួនខ្លាបមុន ដូចពាក្យបុរាណថា ខ្លួនខ្លាមិនខ្លាច ទៅខ្លាចឯស្រមោលខ្លាវិញ ។ លោទិតឆ្លើយថា ខ្ញុំបានជ្រាបស្គាល់ចិត្តតាំងតុះមកពីដើម ប្រាកដជាមនុស្សចិត្តអាក្រក់ បើបណ្ដោយឲ្យចូលមកក្នុងក្រុងហើយ គង់នឹងកើតចលាចលដូចជាពាក្យតេះថាយថាជាប្រាកដ ។

ហូជិនតបថា អ្នកទាំងអស់គ្នាកុំនិយាយយើងមិនស្តាប់ទេ លោកខិតខំ គេះថាយនឹងអស់អាហ៊ានទាំងក្នុង លុះបានឮសំដីហូជិននិយាយដូច្នោះ ក៏ខឹងក្តួចចិត្តណាស់ ខ្ញុះលើកត្រាសំរាប់ការជូនហើយក៏លាចេញលែងធ្វើ កងការ វិលទៅនៅផ្ទះសព្វខ្លួនជាប្រក្រតី ។ ហូជិនទើបចាត់ក្នាក់ការកាន់ ព្រះតម្រាស់ឲ្យចេញទៅទទួលតាំងតុះ។ ក៏លើកពលចូលមកតាំងនៅទី តំបន់លុកតឹក្សែកំពែងក្រុង ។

ឯខន្ទី ១០ នាក់ដឹងថា តាំងតុះលើកទាហានចូលមកតាំងនៅជិត ក្រុងហើយ ទើបគិតគ្នាថា ហេតុទាំងនេះ ពីព្រោះហូជិនជាជើងគំនិតគិត អែបព្រះតម្រាស់ឲ្យខ្មែរក្រៅលើកកងទ័ពមកធ្វើអន្តរាយដល់យើង បើ ប្រសិនជាយើងនៅស្ងៀម សេចក្តីអន្តរាយនោះគង់នឹងមានដល់ជីវិតយើង ប៉ុណ្ណោះ ត្បិតតែយើងនឹងគិតសម្លាប់ហូជិនចេញជាមុនសិន, លុះគិត ព្រមព្រៀងគ្នាហើយទើបចាត់ប្រើមនុស្សទំនុកទុកចិត្ត ៥០ នាក់ ឲ្យ ក្រៀនសស្ត្រាវុធទៅអែបប្រចាំទ្វារព្រះបរមរាជវាំងខាងក្នុង ហើយបង្គាប់ថា បើវេលាណាបានឃើញហូជិនចូលមក ឲ្យព្រួតគ្នាចូលចាប់ចងប់បោលចុះ ខ្លួនទៀតរៀនក៏ចូលទៅទូលព្រះនាងហូះហៅថា ហូជិនអែបព្រះតម្រាស់ បង្គាប់ឲ្យខ្មែរក្រៅលើកទាហានជាធំទ័ព ចូលមកមិនតាប់ទូលព្រះ បង្គំជាខ្ញុំទាំងឡាយសម្លាប់ចោល ទូលព្រះបង្គំជាខ្ញុំទាំងឡាយមិនមាន ទីពឹងឯទៀតសោះ បំពោះមានតែត្រីបព្រះអង្គ សូមព្រះអង្គទទួលព្រះ

ករុណាជួយឲ្យទូលព្រះបង្គំជាខ្ញុំទាំងឡាយរួចរស់ជីវិតក្រោមល្អងធូលីព្រះ
បាទតទៅ ព្រះនាងហូយោ ខានព្រះសវនីយ៍បង្គាប់ថា ឲ្យអ្នកបល់គ្នា
ទៅអង្គុយលង់ត្រួសុំទោសហ្វូដិនចុះ ហ្វូដិនគង់នឹងមានសេចក្ដីករុណាតកតញ្ញូ
មិនបានធ្វើសេចក្ដីអន្តរាយទេ ៗ ភៀសយៀវទូលតបថា ហ្វូដិននោះ
មានចិត្តស្អប់ទូលព្រះបង្គំជាខ្ញុំទាំង ១០ នាក់ណាស់ ដែលទ្រង់ថា ឲ្យ
ទូលព្រះបង្គំជាខ្ញុំទាំងឡាយទៅរកហ្វូដិននោះ ប្រដូចយកសាច់ទៅឲ្យខ្លា
ទីងមិនគង់ជីវិតវិលមកវិញបានទេ បើព្រះអង្គមេត្តាប្រោសទូលព្រះបង្គំ
ជាខ្ញុំទាំងឡាយ សូមទ្រង់ឲ្យអញ្ជើញហ្វូដិនចូលមក ក្រាសសុំអាយុ
ជីវិតទូលព្រះបង្គំជាខ្ញុំទាំងឡាយជួលព្រះអង្គ បើប្រសិនជាហ្វូដិនមិន
មេត្តាទេ ទូលព្រះបង្គំជាខ្ញុំទាំងឡាយសូមទទួលថ្វាយជីវិតទាំងអស់គ្នា
ចំពោះព្រះភក្ត្រតែម្ដងទៅចុះ ព្រះនាងហូយោទ្រង់ព្រះសណ្ដាប់ក៏ប្រាប់
ព្រះទ័យមានសេចក្ដីករុណាណាស់ ទើបចាត់បម្រើឲ្យទៅអញ្ជើញហ្វូដិន
ចូលមកគាល់ ៗ ឯហ្វូដិនចូលទីនគរបែរខ្លួនចូលទៅគាល់ព្រះនាងហូយោ
នោះ គាត់លើកឃាត់ថា ដែលព្រះនាងហូយោឲ្យអញ្ជើញលោកទៅ
គាល់នោះ ខ្ញុំបាទមានសេចក្ដីគិតគាល់ណាស់ ក្រែងមានសេចក្ដីអន្តរាយ
ដល់ខ្លួនលោក ហ្វូដិនទូលថា ព្រះនាងហូយោទីងយើងជាបងប្អូននឹងគ្នា
កាលណាទីនគរបង្កើតជ មិត្រទ្រស្ដុចូលធ្វើតទ័ពទូរទាំង ១០ នាក់នោះ
ឡើយ ៗ អ្នកសៀរក៏ឆ្លើយថា ដាដែលយើងគិតខុសនោះ ប្រហែល

ខ្ទី ១០ នាក់ដឹងជាក់ប្រាកដ យើងខឹងចូលទៅពុំបាន ។ បបួលថា បើលោកខឹងចង់ចូលទៅក៏ទៅចុះ តែត្រូវសុំឲ្យខ្ទី ១០ នាក់ចេញមកពីក្នុងព្រះបរមរាជវាំងសិន ទើបលោកមិនមានអន្តរាយ ហួជិនបានឮអ្នកទាំង ៣ និយាយដូច្នោះក៏សើចហើយតបថា យើងជាមន្ត្រីធំសម្រេចបញ្ជការផែនដីមិនមានអ្នកឯណាស្មើ ខ្ទី ១០ នាក់ប៉ុណ្ណោះ ក៏នឹងមានសេចក្តីគិតភ្ញៀវភ្ញាក់ទៅពុំបាន ក៏ខឹងធ្វើយើងដូចម្តេចបាន អ្នកសៀវថាលោកខឹងចូលទៅក៏ទៅចុះ តែខ្ញុំបាទសុំទៅជាមួយផង អ្នកសៀវទើបឲ្យអ្នកស៊ុតជាប្អូន ឃុំនាំទាហាន ៥០០ ចូលទៅនៅចាំត្រង់ទ្វារវាំងខាងមុខ អ្នកសៀវទើបចូលតែងខ្លួនពាក់ក្រោះកាន់ក្រប៊ីចូលទៅជាមួយខឹងហួជិនដល់ទ្វារខាងក្នុង ពៅអ៊ុំឆាយទ្វារក៏ឃាត់ហាមអ្នកសៀវទើងបួនមិនឲ្យចូលទៅឲ្យនៅខាងក្រៅ ហួជិនក៏ដើរចូលទៅតែម្នាក់ឯងលុះដល់ស៊ុំទ្វារខាងក្នុង កៀវយៀងគួនទុយឃើញហួជិនដើរចូលមកក៏កាំងផ្លូវហើយញាក់មុខឲ្យពួកហាសិបនាក់ហោមព័ទ្ធចាប់ហួជិនបាន ហើយកៀវយៀងនៃស្រែកថា ខ្លួនឯងនេះពីដើមជាមនុស្សតូចទាបណាស់ យើងបានជួយទំនុកបំរុងយកសេចក្តីគិតទូលសុំឲ្យខ្លួនឯងបានធ្វើជាធំដល់ទីនេះហេតុម្តេចឯងក៏ចិត្តធំម្ល៉េះ ហ៊ានប្រើមនុស្សទៅលបសម្លាប់ព្រះនាងតាំងថៃហាជាព្រះមាតាព្រះចៅឡើងគេ ដែលមិនមានសេចក្តីខុសសោះឲ្យទិវង្គតទៅ ហើយខ្លួនឯងក្លែងសែងធ្វើព្រះតម្រាស់ចេញទៅខែត្រក្រៅ

ឲ្យលើកទាហានចូលមកទឹងតាប់ខ្លួនយើង ដែលមានគុណូបការៈដល់ខ្លួន នោះសម្លាប់ទៀត ខ្លួនឯងនេះជាមនុស្សគ្មានសេចក្ដីកតញ្ញូនឹងយើងសោះ ត្រឡប់ថ្កោលទោសថា យើងជាសត្រូវនឹងរកផលសម្បត្តិវិញ ខ្លួនឯងគិតប្រទូស្តរ៉ាយនឹងយើងហើយ យើងត្រូវយកជីវិតខ្លួនចេញក្នុងវេលានេះ ។

ហ្វូជិនឈរជាប់ក្នុងបំណោមដំពង់ទឹកដូច្នោះក៏តក់ស្លុតខ្លួនស្ទើរនឹងធ្លាក់ស្មារតីផុតនិស្ស័យ ដែលនឹងរកទីពឹងប្រឹងក្រឡេកមើលទៅទ្វារខាងក្រោយបិទជិតឈឹង ពួកទាហានមកសំពងាក់ក៏ប្រហារហ្វូជិនអនិច្ចកម្មនៅទីនោះឯង ។

ឯអ្នកសៀវនឹងចូលឈររេកខាងក្រៅទ្វារចាំយូរណាស់ មិនឃើញហ្វូជិនចេញមកក៏ស្រែកហៅពីក្រៅ គៀវយៀនបានឮសំឡេងក៏កាត់ក្បាលហ្វូជិនត្រៃវែងបោះចេញមក ហើយស្រែកប្រាប់ថា ហ្វូជិនគិតក្បត់ យើងសម្លាប់ចេញហើយយកក្បាលទៅចុះ នរណាដែលមិនបានចូលដៃរួមគំនិតក្បត់ជាមួយទេ ឲ្យវិលត្រឡប់ជាប្រញាប់ទៅវិញចុះ កុំមកតកជាគូឡើយ ។ អ្នកសៀវនឹងចូលបានឮដូច្នោះក៏ស្រែកប្រកាសថា ហ្វូជិនជាសេនាបតីសម្រេចផលការផែនដី ខ្ញុំ ១០ នាក់រួមគំនិតគ្នាតាប់ហ្វូជិនសម្លាប់ហើយ យើងត្រូវតែចំលាយទ្វារកំនត់ចូលទៅសម្លាប់ខ្ញុំ ១០ នាក់ ឲ្យអស់ចេញ នរណាចូលដៃនឹងយើងខ្លះ ។ ឆោខង

ជាទាហានហ្វូងដែលទៅជាមួយនឹងអ្នកស៊ុក ក្រុមអ្នកសៀវនិងប៊ូ ស្រែក ថាដូរហោះ ក៏យកភ្លើងដុតទំលាយទ្វារព្រះបរមរាជវាំង ហើយអ្នកស៊ុក ក៏ដេញពួកទាហានចូលទៅបានប្រទះនឹងខ្ទីលេវ ទាំងពួកក៏ចាប់សម្លាប់អស់ អ្នកសៀវប៊ូក៏ស្ទុះចូលទៅទៀត ខណៈនោះ តៀវកុន តៀវអ៊ួន វៃហ៊ុយ គុយសេង ខន្ទីទាំង ៤ នាក់នេះ ឃើញអ្នកសៀវ ប៊ូ នឹងអ្នកស៊ុក ទំលាយទ្វារព្រះបរមរាជវាំងចូលមក ក៏ស្ទុះរត់រាំងចូលទៅក្នុងសួនផ្កា អ្នកសៀវ ប៊ូ ដេញតាមសម្លាប់នៅទីនោះ ហើយបញ្ជាំកាប់ខន្ទី ៤ នាក់ រាល់តែល្អិតខ្ទេចខ្ទីអស់ទៅ ឯភ្លើងក៏ឆេះរាលចូលដោយដល់តំណាក់ខាងក្នុង តៀវហៀង គួនគុយ ថៅថៀក ហៅឡាំឃើញអណ្ដាតភ្លើងឆេះសន្ធោសន្ធៅ ក៏នាំព្រះនាងហូហៅទឹងហាងជូតៀន នាងជូហៀង រត់គេចទៅត្រង់កន្លែងដែលភ្លើងមិនទាន់ឆេះទៅដល់នោះ ។

ខណៈនោះ លោទិតដែលបញ្ចាតពីតំណែងមន្ត្រីហើយនោះ លុះឃើញពន្លឺភ្លើងឆេះក្នុងព្រះបរមរាជវាំង ក៏កេនខ្លួនពាក់គ្រោះកាន់អាវុធទៅឈរនៃមាត់ទ្វារល្អកក្រសួងទៅ លុះគ្រាឡើងទៅឃើញគួនគុយ ហូហៅនគររត់ពីភ្លើងក៏ស្រែកសួរទៅថា គាត់ក្រាបសង្គ្រោះព្រះនាងរត់ទៅណា ។ គួនគុយបានព្រួសមែកត្រឡប់ទៅឃើញលោទិត ក៏ភិតភ័យរត់គេចចេញពីទីនោះ ព្រះនាងហូហៅក៏ភ័យស្លុតលោតចំឡាក់ខ្លួនពីលើរបៀងតំណាក់លោទិតរត់ចូលទៅកន្លែងទំពាំង ដៅខាង

ឃុំទាហានចូលទៅដល់ក្នុងកំពង់ ប្រទះនឹងហ្វូងវៀតកៅ ស្រែកថា អាទេះ សត្រូវនឹងជាតិសម្បត្តិ ៗ អាឯងនឹងរួមគំនិតនឹងខ្ញុំ ១០ នាក់សម្លាប់ហ្វូងជន បងឯង អញសម្លាប់អាឯងវិញឲ្យបាន ពួកទាហានក៏ស្ទុះស្រែចូលទៅ ព័ទ្ធចាប់សម្លាប់ហ្វូងវៀតបាន ៗ

បណ្ដាទាហានទុរ្ទមន្រ្ទីចំពុះផ្ទះទើនសេនាទាហានទាំងពួង សឹងចូល ទៅជាពួកក្រុមនៃអ្នកសៀមនឹងពួកជាប្រើន ទើបអ្នកសៀមចាត់ទាហាន ១ កងតាមទៅព័ទ្ធចាប់ខ្ញុំ ១០ នាក់ នឹងបក្ខពួកទាំងប្រុសទាំងស្រីគួបធំ សម្លាប់អស់ ហើយប្ដូរក៏ឃុំនាំទាហានចូលទៅលក់ភ្លើងដែលនេះក្នុងព្រះ បរមរាជវាំងលក់ស្រេច ក៏ញញ្ញែញៈស្ដេចព្រះនាងហ្វូងហៅទៅស្ដែកផ្ទះ ផែនដីដូចដើម លុះវេលាយប់គួនទុយក៏តែទៅជួបនឹងគៀវយៀង ទើប បបួលគ្នានាំហាងជួរៀន ហង់ជួញបរតេចេញទៅនៅក្រៅក្រុងលាក់ខ្លួន ពួនក្រែកក្នុងព្រៃប្របដើមក្បាច់ត្បូសាន ៗ

ឯអ្នកសៀមនឹងប្ដូរក៏កេណ្ឌប្រមូលពលទាហានបែកជា ២ កង កង មួយឲ្យតាមចាប់ពួកខ្ញុំ ៦ នាក់ កងមួយឲ្យតាមស៊ើបរកហាងជួរៀននឹង ហាងជួញបក្នុងវាក្រៅក្រុង ខណៈដែលគួនទុយនឹងគៀវយៀងបានឮ ស្ទូរសំឡេងទាហានទៅគ្រានតាមទៅជញ្ជាន់រកសន្ធឹកណាស់ ក៏ភ័យខ្លាច ក្រែងមិនរួចពីសេចក្ដីស្លាប់ ទើបប្រញាប់ដោះវែះគេចយកខ្លួន ឯព្រះ កដទ្រសេចាំងពីព្រៃអគ្គ ក៏បោះបង់ចោលទៅក្នុងព្រៃកណ្ដាលអព្រៃ

ស្ងាត់ ឯតៀវយៀនក៏កាត់តាមផ្លូវដើរតោតទៅដល់ស្ទឹង ១ ប្រទះនឹងមនទ័ពចិនខាងហោហ្វាយ ស្រុកហោឡាំ ពួកទាហានមិនបានឃើញខ្លួនតៀវយៀនឮតែសូរដើរដើរក្នុងព្រៃព្រាត ៗ ក៏នាំគ្នាព័ទ្ធក្បែរមាត់ស្ទឹងនោះ លុះដុតគប់ក្អែងបងទឹងមែកឈើចំកូលទៅ ឃើញជាមនុស្ស តៀវយៀនក៏ស្ទុះលោតទៅក្នុងស្ទឹងលង់ទឹកស្លាប់ទៅ ។

ឯហានជូពៀនទិនហានជូហៀប ដែលខ្ទីបោះបង់ចោលក្នុងព្រៃ លុះបានឮសំឡេងពលទាហានខ្លាំងព្រៃចូលមកអ៊ឹកកងដូច្នោះ ក៏ទ្រង់ភ័យណាស់ ដល់ពេលយាម ៣ ទើបសន្សើមធ្លាក់ណាស់ ក៏ប្រឹក្សាគ្នាថា យើងនៅក្នុងទីនេះមិនបានទេ ត្រូវតែចេញទៅទើបផុតភ័យអន្តរាយ ថាហើយក៏នាំគ្នាយានព្រះបាទសស្រុលមមុលព្រៃទៅក្នុងវេលាកណ្ដាលយប់ងងឹតមើលផ្លូវមិនឃើញសោះ មិនដឹងនឹងទិសទៅខាងណា ក៏យកជាយព្រះភូសាចងភ្ជាប់គ្នា លុះក្រឡេកឃើញអំពិលអំពែកហើរនាំមុខ ១ ហ្វូងក៏ភ្លឺស្វាងឃើញច្រកល្ហក ក៏នាំគ្នាយានទៅតាមពន្លឺអំពិលអំពែកនោះ ហានជូហៀបថា ព្រះអនុជមានបន្ទូលថា អំពិលអំពែកនេះគឺជាទេវតាជួយនាំផ្លូវយើងជាប្រាកដ អំណើះទៅមុខយើងនឹងមានបុណ្យ លុះវេលាជិតភ្លឺស្រាងក៏យានទៅដល់ភូមិមួយអន្ទើ ព្រះបាទព្រះជជកុមារទាំង ២ ព្រះអង្គ ក៏ហើមព្រះបាទនឹងយានទៅមិនបាន លុះទ្រង់

គេទៀតមើលទៅឃើញគំនរស្មៅ ១ គេក៏នាំគ្នាចូលទៅប្រះផ្ទុលកលន់ពុំ ដឹងព្រះកាយា ។

ទីនោះមានបំណាច់ណាំរបស់អ្នកស្រុកម្នាក់ឈ្មោះស៊ុយកុក គន់ ពេលយប់នោះ ស៊ុយកុកដេកលក់យល់សប្ដិឃើញថា មានព្រះអាទិត្យ ២ ដួងធ្លាក់នៅទីលានក្រោមផ្ទះ លុះព្រឹកឡើងស៊ុយកុកភ្ញាក់ឡើងពីដេក ក៏ដើរចេញទៅលានខាងក្រោមផ្ទះក្រឡេកទៅឃើញស្មៅគ្រប់គំនរស្មៅ ក៏ដើរចូលទៅមើលឃើញកុមារ ២ នាក់ដេកប្រកបគ្នា ស៊ុយកុកក៏សាកសួរឡើងសួរថា កុមារនេះមកពីណា? អេនដូរៀបឆ្លើយថា នោះព្រះនាមឈ្មោះហានដូរៀនដែលសោយរាជសម្បត្តិនគរក្រុងឡូកអៀង យើងជាព្រះអនុជឈ្មោះតាន់លីអេង បានជាយើងតែមនៅស្រែគនទីនេះ ព្រោះតែខន្ទី ១០ នាក់ បណ្ដាលឲ្យកើតចលាចលវរវៃនគរ ព្រះនគរ ។ ស៊ុយកុកបានឮដូច្នោះ ក៏គក់ស្ទុះលុតជង្គង់ចុះក្រាបថ្វាយបង្គំហើយទូលថា ទូលព្រះបង្គំជាខ្ញុំឈ្មោះស៊ុយកុក ពីដើមបានចូលធ្វើជាខុនជាងក្នុងក្រុងដែរ តាំងតែពីផែនដីព្រះចៅទៀនតេជាព្រះវរពង្សពិតានៃព្រះអង្គ ខន្ទី ១០ នាក់ ធ្វើការទុច្ចរិតការគ្រប់ផ្សេងៗ ទូលព្រះបង្គំជាខ្ញុំមិនសប្បាយចិត្តមិនចង់ធ្វើជាការ ក៏លាឈប់ចេញមកធ្វើស្រែចំការនេះទូលទាននៅទីនេះ ទូលហើយស៊ុយកុកក៏អញ្ជើញព្រះរាជកុមារទាំងពីរព្រះអង្គឡើងទៅគង់លើផ្ទះ ហើយក៏រៀបចំថ្វាយ

ប្រដាប់ទីប្រដាប់ត្រយោះស្លាបះប៉ាអោតារមារ ខណៈនោះ ព្រះរាជកុមារទាំងពីរព្រះអង្គ ក៏គង់សម្រាកនៅផ្ទះស៊ុយកុក ។

ឯចិនខនក៏លើកពាហានចូលមកប្រទះនឹងកូនកុយខ្ទុំ ទាហានក៏ឃុំចាប់ខ្លួនបាន ចិនខនពិចារណាសួរថា កើតហេតុបណ្ដាលគ្រោះនេះព្រោះពួកឯងទាំង ១០ នាក់បណ្ដាលឲ្យរកាត្រក់ផ្សេងៗ ខ្លួនឯងនាំព្រះរាជ-កុមារទាំងពីរព្រះអង្គទៅទុកឯណា ។ កូនកុយទើបតបថា កាលកើតភ្លើងឆេះឡើងក្នុងព្រះបរមរាជវាំង ខ្ញុំបាននាំព្រះរាជបុត្រទៅនៅក្នុងព្រៃ លុះថ្ងៃក្រោយឡើងពួកកងទ័ពចូលមករករើកពួកទាហាន ខ្ញុំបានក៏មានសេចក្ដីតក់ស្លុតភ័យណាស់ក៏រត់ប្រាសចាកគ្នា ឯព្រះរាជ-កុមារ ២ ព្រះអង្គបានបួសក៏អត់ដឹងជាគង់ទៅទីណា ។ ចិនខនឮដូច្នោះខឹងណាស់ ក៏ឲ្យសម្លាប់កូនកុយទៅនោះហើយកាត់យកក្បាលព្យួរនឹងគសេះ លើកពាហានចេញពីនោះដើរតាមផ្លូវ តាមទៅរកព្រះរាជបុត្រទាំង ២ ព្រះអង្គ ឯចិនខនជិះលើខ្នងសេះតក្រុកព្រៃវែងរកព្រះរាជបុត្រ ដោយហេតុនឹងទេវតានាំឲ្យមិនត្រង់ទៅដល់មាត់ក្លោលផ្ទះស៊ុយកុក ។

គ្រានោះ ស៊ុយកុកឈរនៅមុខផ្ទះ លុះក្រឡេកឃើញចិនខនចងក្បាលកូនកុយព្យួរនឹងគសេះ គេចូលមកដល់ក្លោះតាក្បា ក៏ម៉្យាងទៅជិតពិនិត្យក៏ស្គាល់បាន ទើបសួរថា លោកចាប់ខ្លួនកូនកុយបានទៅទីណា

ទើបកាត់ក្បាលព្យួរទឹងអស់នោះនាំមកនេះ ។ ប៊ិនខេងឆ្លើយឲ្យដំណឹងស៊ុយកុកតាំងពីដើមដល់ចប់សព្វគ្រប់ហើយ ។ ខ្ញុំសូមទុកដល់ថ្ងៃនេះដើម្បីទឹងស៊ីបានព្រះរាជបុត្រទាំង ២ ព្រះអង្គ ស៊ុយកុកក៏នាំត្រមង់ចូលទៅក្រាបបង្គំគាល់ដល់ក្សត្រផង ហើយស៊ុយកុកទឹងប៊ិនខេង ក៏យកសេចក្តីក្រាបបង្គំទូលព្រះរាជកុមារទាំងពីរថា ជំនឿមកពីប្រពៃណីតាំងពីបុរាណមកវត្តនារីកេរ្តិ៍កថា ប្រែថាសង្ខរណា បើគ្នាអស់ខ្មែរខែជីស្មោះយកជ-សម្បត្តិ សម្បត្តិ ១ ថៃ ថែខជីនោះ ទឹងក៏គបលាបលទៅជាមានអន្តរាយទំនាស ហេតុនេះសូមមានព្រះអង្គវិលនៅគង់ក្នុងនគរដូចដើមវិញទើបផែនដីទីនោះបានសេចក្តីសុខសប្បាយតទៅ ។

ព្រះរាជកុមារទាំងពីរព្រះអង្គទ្រង់ព្រះសណ្ដាប់ ក៏គាប់ព្រះហឫទ័យព្រមតាមសំដីដែលក្រាបបង្គំទូលនោះ ស៊ុយកុកទឹងប៊ិនខេង ក៏រៀបចំគ្រឿងសេះព្រះទីនាំងដែលសំរាំងកុកក្យាយ ហើយក៏អញ្ជើញស្តេចឡើងគង់ទ្រង់យានចេញទៅ លុះទៅដល់ផ្លូវប្រមាណ ៣០០ សិន (១២ គីឡូម៉ែត្រ) ជួបប្រទះនឹងឈ្មោះ អង់ស៊ុន ១, អីពៅ ១, ស៊ុនខេន ១, កៀវប៉េង ១, ប៉ោ ស៊ុន ១, អូនសៀវ ១ ជានាហ្មឺនមានបណ្ដាស័ក្តិ យុំនាំពលទាហានប្រមាណ ៨០០ នាក់ លើកការមកតាម អ្នកទាំងនេះលុះគ្រាន់ឃើញព្រះរាជកុមារទាំង ២ អង្គ ក៏ជម្រាបម្រងសេះចុះទៅទូលស្តេច ។ វេលានោះស៊ុយកុកទឹងប៊ិនខេង

ក៏ពណ៌នាសេចក្ដីដែលបានទៅគេឃើញព្រះរាជកុមារ ឲ្យស្លាប់គ្រប់ប្រការ បណ្ដានាហ្មឺនទាំង ៦ នាក់លុះបានស្ដាប់ដាច់ហើយក៏ចាត់ចែងសេះឲ្យនាំយកក្បាលអ្នកទុយ ស្រែកត្រូវចូលទៅប្រកាសឲ្យអស់បណ្ដារាស្ត្រនៅក្នុងព្រះនគរឲ្យបានដឹងគ្រប់គ្នា ហើយប្រាប់ពួកក្រុមខ្ញុំរាជការចាត់ព្រះរាជរថដ៏វិចិត្របនាសម្រាប់ព្រះមហាក្សត្រ ចេញទៅទទួលព្រះរាជកុមារទាំង ២ ព្រះអង្គ ចម្ងាយផ្លូវប្រមាណ ១០០ សិន (៤ គីឡូម៉ែត្រ) ស្ដេចក៏ឡើងគង់គ្រឡប់ ទទួលជួបប្រទះនឹងតាហានមួយកងច្រើនខ្ទង់ខ្ទាប់តែពុំដឹងច្បាស់ជាពួកនៃទ័ពអ្នកឯណា អស់ពួកខ្ញុំរាជការទាំងឡាយក៏កើតភ័យ អ្នកសៀវជានាយតាហានក៏បំផាយសេះស្រូតទៅមុខព្រះរាជរថ ហើយស្រែកសួរថា ទ័ពអ្នកឯណាលើកមកនេះ តាំងគុះជាមេទ័ពក៏ប្រញាប់ចុះសេះដែលទៅមុខតាហានហើយឆ្លើយតបថា ព្រះរាជកុមារនៅឯណា ឬស្ដេចយាងមកជាមួយពួកនេះ ហានជូពៀនទ្រង់ព្រះសណ្ដាប់ក៏ស្ងប់ព្រះទ័យសៀមនៅ ចំណែកហានជូហៀបជាព្រះអនុជក៏ឆ្លើយឡើងថា ទ័ពអ្នកឯណាសួររកព្រះរាជកុមារ ៗ តាំងគុះក៏ឆ្លើយថាខ្ញុំឈ្មោះតាំងគុះជាចៅហ្វាយស្រុកស៊ីឡូន ហានជូហៀបត្រាស់សួរបញ្ជាក់ថា មកនេះជាក្បត់ឬប្រាថ្នាវត្ថុ ? តាំងគុះថាខ្ញុំមិនមែនជាក្បត់ទេ គឺមកទទួលស្ដេច ៗ ហានជូហៀបត្រាស់ថា បើមកទទួលស្ដេចហេតុម្ដេចមិនចុះពីលើសេះ តាំងគុះឮដូច្នេះភ័យណាស់ ក៏លោតចុះពីលើខ្នងសេះ

(មានត)

# ការជូនរង្វាន់ដល់អ្នកប្រឡងជាប់
## ទំនៀមទម្លាប់ខ្មែរ

ក្នុងឆមាស ខាងចុងនៃឆ្នាំ ១៩៦៨ គឺតាំងពីខែកក្កដាដល់ខែធ្នូ នោះក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ បានប្រកាសការប្រឡង ២ រឿង គឺរបររកស៊ី ១ រឿង ល្បែង ១ រឿង ។

មានបេក្ខជនច្រើននាក់ បុរសខ្លះ ស្ត្រីខ្លះ បព្វជិតខ្លះ បានតែងរឿងជាច្រើនផ្ញើទៅប្រឡង ។ ក្រុមជំនុំមានសេចក្ដីអរគុណជាច្រើន ។

ក្រុមជំនុំបានជួបជុំពិនិត្យឃើញរឿងរបររកស៊ី ៧ រឿង រឿងល្បែង ៣ រឿងរួមជា ១០ រឿង មានពិន្ទុច្រើនជាងគេ បានព្រមព្រៀងឲ្យរឿងទាំង ១០ នោះ ជាប់លេខបានជូនរង្វាន់តាមថ្នាក់ ដូចរាយឈ្មោះតទៅនេះ

## រឿងរបរ បានជាប់ ៣ នាក់ គឺ:

១ - លោក ឌិញ - ប្រាជ្ញ អាចារ្យបង្រៀននៅក្រសួងពុទ្ធសាសន-បណ្ឌិត្យនេះ ខែត្រឃ្លាំងកូស័ងស៊ីន តែងរឿង ការធ្វើស្រែ បានជាប់លេខ ១ ត្រូវបានរង្វាន់ ៦០ រៀល ។

២ នាងនេត - ឡាំងស៊ី នៅភូមិគេងកង ឃុំលេខ ៦ ភ្នំពេញ តែងរឿងបេះថ្នាំ បានជាប់លេខ ១ ត្រូវបានរង្វាន់ ៦០ រៀល ។

៣- ឃុន សិរីមេធី ស្រី-អ៊ូ ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសា-សនបណ្ឌិត្យ ភ្នំពេញ តែងរឿង ការធ្វើស្រែ បានជាប់លេខ២ ត្រូវបានរង្វាន់ ៤៥ រៀល ។

៤- លោកគូ-គួ អាចារ្យវត្តត្រពាំង ឃុំដំដែក ស្រុកសូទ្រនិគម ខេត្តសៀមរាប តែងរឿងការយកឃ្មុំ បានជាប់លេខ២ ត្រូវបានរង្វាន់ ៤៥ រៀល ។

៥- លោកភិក្ខុ ឈឹម-សាវេត គង់វត្តឧណ្ណាលោម ភ្នំពេញ សិស្សសាលាបាលីជាន់ខ្ពស់ តែងរឿង ការធ្វើស្រែ បានជាប់លេខ ៣ ត្រូវបានរង្វាន់ ៣០ រៀល ។

៦- លោកជា-ជួន នៅឃុំចំនត្រំ ស្រុកល្វាឯម ខេត្តកណ្ដាល តែងរឿងការធ្វើសំពត់ហូល ជាមួន-សារុន បានជាប់លេខ ៣ ត្រូវបានរង្វាន់ ៣០ រៀល ។

៧- លោក ជាប់-ស្រាក់ គ្រូបង្រៀនសិស្ស នៅសាលារៀនតេជោគន្ធូរ ភ្នំពេញ តែងរឿង ការនេសាទត្រី បានជាប់លេខ ៣ ត្រូវបានរង្វាន់ ៣០ រៀល ។

## រឿងល្បែង បានជាប់ ៣ នាក់ គឺៈ

១ លោកសាមណេរព្រាប-ឌិប គង់វត្តលង្កា ភ្នំពេញ សិស្សសាលាបាលីជាន់ខ្ពស់ តែងរឿង ល្បែងប្រណាំងទូក បានជាប់លេខ ១ ត្រូវបានរង្វាន់ ៦០ រៀល ។

២- លោកយោក្សត្រ ម៉ៅ-មុី នៅក្រសួងមហាផ្ទៃ ភ្នំពេញ តែងរឿងល្បែងទាញព្រ័ត្រ បានជាប់លេខ ២ ត្រូវបានរង្វាន់ ៤៥ រៀល ។

៣- លោក ថាច់-ប៉ែន ហៅប៉ុន អាចារ្យបង្រៀននៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ខេត្រឃ្លាំង គូស័ងស៊ុន តែងរឿង ល្បែងប្រណាំងទូក បានជាប់លេខ ៣ ត្រូវបានរង្វាន់ ៣០ រៀល ។

ក្នុងឆមាសខាងដើមនៃឆ្នាំ ១៩៤៩ គឺតាំងពីខែមករានេះ ទៅដល់ដាច់ខែមិថុនា មានការប្រឡងពីររឿងទៀត គឺសារតារវត្ត និងប្រយោជន៍ក្នុងជាតិ ដូចមានកម្មវិធីបោះពុម្ពផ្សាយទៅ ។

សូមអស់លោកទាំងឡាយត្រៀមទុកពេលតែងផ្ញើទៅប្រឡង ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

# បុណ្យបញ្ចុះធាតុ

កាលពីថ្ងៃចន្ទ ៦ កើតខែកត្តិក ឆ្នាំឆ្លូវសំរឹទ្ធិស័ក ព.ស. ២៤៩១ នៅទីវត្តកំពង់ភ្លុក
ឃុំកំពង់ភ្លុក ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

ក្រុមបរិស័ទទាំងគ្រហស្ថទាំងបព្វជិត នៅទីជិត-ឆ្ងាយជាសិស្សានុសិស្សលោកគ្រូព្រះសពសុខ-នួន ចៅអធិការវត្តកំពង់ភ្លុក មានប្រជុំគ្នាធ្វើបុណ្យបញ្ចុះអដ្ឋិធាតុព្រះសពសុខ-នួន ក្នុងចេតិយនៅទីវត្តនោះ យ៉ាងមហោឡារិកអធិកធំសំបើមអស្ចារ្យ ហើយមានទាំងសុន្ទរកថា សូត្រប្រារព្ធសរសើរកិត្តិគុណ និងឧទ្ទិសផលបុណ្យប្រគេនទៅលោកគ្រូព្រះសពនោះ ដូចមានសេចក្ដីទៅនេះ ;

## សុន្ទរកថា

សូមពិតបេរ៉ាទា និងសូមជំរាបអស់លោក-អ្នកទាំងអស់គ្នាជាក្រុមបរិស័ទ ទាំងគ្រហស្ថទាំងបព្វជិតដែលនិមន្តនិងអញ្ជើញមកពីទីជិត-ឆ្ងាយ សូមជ្រាប ៖

ថ្ងៃនេះ ជាថ្ងៃសុខក្ខត្តឫក្សល្អ ទាំងពេលវេលាក៏ជាមង្គលដ៏ប្រសើរពន់ពេកណាស់, ដែលក្នុងឱកាសនេះលោកគ្រូចៅអធិការ អ៊ិត-ហេង ជាសិស្សច្បងរបស់ព្រះសព, និងលោកគ្រូចៅអធិការ ជូ-ប៊ុល វត្តខ្នងភ្នំក្រោម (សៀមរាប) ជាគូឧធម៌សំណប់នៃព្រះសពសុខ-នួន និងលោកគ្រូស្រូតស្តាំព្រះនាម ស្រី-សួរ និងអ្នកមេឃុំ អ្នមអ៊ុក-សម

ព្រមតាយាយ សួត ជាភរិយា, អ្នកជំទប់ត្រាំ-លឿង តាយាយ យឿន, អ្នកជំទប់ប្រែក-ផាត់ តាយាយ ហោ, អ្នកជំទប់ងួនឆុយ តាយាយ គួន មីងអ្នកជស្តៅ នូ-កៀវ តាយាយ ញ៉ឹន, អ្នកមេឃុំថាវ-ហ៊ុយ ខុបាសិកា គ៉ំ, អ្នកជស្តៅ ផាប់-ឆាយ តាយាយ ហ៊ិន, អ្នកជស្តៅ ផាន់ តាយាយ អ៊ិន, អ្នកជស្តៅ លុយ តាយាយ គីម, អ្នកជស្តៅ សេន តាយាយ ម៉ៃ, អ្នកជស្តៅ យ៉ែន តាយាយ ហ៊ិ, អ្នកជស្តៅ ង៉ឺន តាយាយ អ៊ុត, អ្នកជស្តៅ ហេង តាយាយ ម៉ី, អ្នកជស្តៅ ជួន តាយាយ លី, អ្នកជស្តៅ ប៉ាត តាយាយ ហែម ជាដើម ព្រមទាំងក្រុមសិស្សានុសិស្សគួប ចំនៅក្នុងជីក-ឆ្ងាយ មកប្រជុំគ្នាធ្វើបុណ្យនេះ ហើយមានថ្លែងប្រវត្តិរៀងរ៉ាវព្រះសពសុខ-ខួនខ្វាំ បន្តិចជាកិច្ចខាងដើម ថែកជូនដល់លោកអ្នកជាក្រុមសប្បុរសទាំងឡាយស្តាប់ដូចមានសេចក្តីទៅនេះ

លោក-អ្នកក្រុមពុទ្ធបរិស័ទទាំងឡាយ! ព្រះតេជព្រះគុណព្រះសពសុខ-ខួននេះ មាតាឈ្មោះអែម បិតាឈ្មោះសុខ លោកកើតថ្ងៃសុក្រ ខែពិសាខ ឆ្នាំបបញ្ចស័ក (ក្នុងព.ស. ២៤១៥ គ.ស. ១៨៧២) លុះអាយុ ១៨ ឆ្នាំ បាននៅវត្តសិក្សាអក្សរសាស្ត្រក្នុងសំណាក់លោកគ្រូរស់ អាយុ ២១ ឆ្នាំ បួសជាសាមណេរក្នុងសំណាក់លោកគ្រូរស់ អាយុ ២២ ឆ្នាំ ឧបសម្បទាជាភិក្ខុភាវៈក្នុងសំណាក់លោកគ្រូរស់ អាយុ ២៤ ឆ្នាំ បួសបាន ៣ វស្សា បានធ្វើជាគ្រូស្រែ ហើយលោកបានតសាងកុដិ

ធំ ១ ខ្នងក្នុងទីវត្ត សាងសាលាសំណាក់ ១ ខ្នងនៅភូមិបង្គោរ លុះដល់មកអាយុ ៣១ ឆ្នាំ វស្សាបាន ៩ វស្សា បានឡើងទីជាចៅអធិការ ហើយលោកកសាងខឿនវិហារបៀបថ្ម ១ ជុំ សាងកុដិធំ ១ ខ្នង សាលា-ធម្មសំរាប់ធ្វើបុណ្យ ១ ខ្នង សាលាឆាន់ ១ ខ្នង សាលាសំរាប់ធ្វើបង្កាន់ ១ ខ្នង សាងផនទឹកចាក់ស៊ីម៉ងត៍ ១ ខ្នង និងបុណ្យផ្សេងៗទៀតជាច្រើន មានហែកឋិន ៨ វត្តជាដើម ។

លុះដល់មកព្រះជន្ម ៧០ ឆ្នាំ វស្សាបាន ៤៩ វស្សា ក៏ចាប់មានអាពាធដោយរោគជរា ពួកសិស្សានុសិស្សទាំងឡាយ ក៏ខំព្យាបាលពេញទំហឹង រោគនោះក៏មិនជាសះស្បើយ លោកក៏ចូលអនិច្ចធម្មទៅនៅថ្ងៃសុក្រ ១០ កើត ខែមាឃ ឆ្នាំមមែ ឆស័ក (ព.ស. ២៤៨៤) ហើយពួកសិស្សានុសិស្សដំកល់សពទុក ១ ឆ្នាំ ទើបនាំគ្នាធ្វើបុណ្យឈាបនកិច្ចសពលោក ។

លុះដល់មកឆ្នាំជូតសំរិទ្ធិស័ក ព.ស. ២៤៩១ ត្រង់.លើខែកត្តិក ៦ រោច ថ្ងៃចន្ទ ពេលម៉ោង ៧ ព្រឹក ពួកសិស្សានុសិស្សនាំគ្នាធ្វើបុណ្យជាឱឡារិកអស់ ៦ ថ្ងៃ ទើបហែព្រះអដ្ឋិធាតុលោកបញ្ចុះក្នុងប្រាង្គសាងថ្មខាងត្បូងព្រះវិហារវត្តនោះ ។

ដោយអំណាចតាមានិសង្ស ដែលយើងខ្ញុំបានព្រមសិស្សានុសិស្ស គួប-ជំបានធ្វើនេះ សូមទទួលសុខត្តមផលប្រគេនចំពោះដៅជូនវិញ្ញាណក្ខន្ធ ព្រះតេជព្រះគុណព្រះសពសុខ - ខួន ជាគ្រូឧបជ្ឈាយ៍ធំនៃយើងខ្ញុំ ។

សូមឲ្យលោកបានទទួលអនុមោទនាយកផលនេះ សោយសេចក្ដីសុខ សេចក្ដីចំរើន តាមប្រាថ្នារបស់លោកចុះ ។

ហើយសូមលោកឲ្យស័ព្ទសាធុការមកយើងខ្ញុំគ្រប់ៗគ្នា ឲ្យបានប្រកបដោយសម្បត្តិ ៣ ប្រការ គឺសម្បត្តិមនុស្ស ១ ទេវតា ១ និងព្រះនិព្វាន ១ ជាទីបំផុត កុំបីឃ្លាតឡើយ ។

ពន្លឺអាស៊ីទិប

# ឃ្លង់និពន្ធមន្ត្រី ញ៉ុក-ថែម ប្រែរៀបរៀង

(តទៅ)

លុះអំណើះពេលតមក - តាំងពលសេចក្តីត្រាស់ដឹងរបស់ព្រះអង្គ បានផ្សាយចេញទៅហើយ មានគេក្រាបទូលសួរព្រះពុទ្ធជាម្ចាស់អំពីរឿងទាំងនោះ គេក្រាបទូលសួរព្រះអង្គថា ព្រោះហេតុអ្វី បានជាព្រះនាងយសោធរ ទ្រង់ស្បៃខ្មៅទឹងមាស ហើយទ្រង់ព្រះជំណើរយាងយាសល្អមើលណាស់, ទើបព្រះអង្គដែលបក្រក់ឡៃកង់នោះពេ ទ្រង់ឆ្លើយថា៖ «ព្រោះអំពីតថាគតគ្មានខណណាដឹងរឿងនេះទេ បើទុកជាមានគេបេះដឹងខ្ញុះ ក៏មិនបានជាពេញលេញល្អទេ ក្នុងខណៈដែលវត្ថុនៃការវិលកើតវិលស្លាប់កំពុងនៅមាន របស់ទាំងឡាយទឹងតំនិតទាំងឡាយ និងជីវិតដែលខ្លួននៅត្រឡប់កើតមានឡើងវិញទៀត ។ ឥឡូវនេះ តថាគតនៅលើគំនិតឃើញ ពេលបើគតជញ្ជះឡើងទៅកប់ដោយលានលោជិត្ថាំ នៅវេលាដែលតថាគតត្រេបត្រោកទៅក្នុងក្តី ដ៏ដោជាសបោយពៃព្រៃព្រឹក្សា នៅឯនិក្ខមហិមាលយា" តថាគតជាសត្វខ្មួយបានសេចក្តីស្រែឃ្លាន ស្បែកមាសឡាយធ្មេញ ដេកនៅក្នុងព្រៃស្បូវក្តាំង យើងចាំគន់មើលដោយភ្នែកក្រឡេតមើលតែព្រឹមៗ ចំពោះហ្វូងសត្វដែលកំពុងត្រីវស្មៅ ចូលមកកាន់តែជិតឡើងៗ តាមមរណៈ ចំពោះសំណាក់របស់យើង ឬមួយនៅ

ក្រោមគកតេអាំងឡាយ យើងដើរត្រូវផ្អាក់ទៅក្នុងព្រៃដោយសេចក្តីស្រេកឃ្លានស្ទើរតែរំពារ ដោយស្រែងតាមក្លិនមនុស្សឬម្រឹគ ៗ ទៅតណ្ហាលព្រៃស្រោងស្រាងដែលជាលំនៅនៃពួកព្យួ កាលណោះ ទៅក្នុងព្រៃញឹក ឬព្រៃនាមដ៏បរិបូណ៌ដោយប្រឡាយទឹក ជាជ្រោះជ្រលងផងអួរ មានព្យុគ្ស ១ មានរូបធោមធេងណាស់នៅក្នុងព្រៃជាហេតុឲ្យពួកព្យុគ្សធ្វើបាបអ៊ំនិងគ្នា សេប្រកនាងព្យុគ្សមានពណ៌មាសក្រឡាខ្មៅ ដូចជាស្បៃត្របុរាដែលនាងយសោធរក្រៃ ក្នុងការបង្ហូរនេះដែរ, ការតស៊ូគ្នាក្នុងព្រៃនោះខ្លាំងក្លាណាស់ ជេញនិងគ្រប់កាផាកាវុធ ខណៈនោះ នាងព្យុគ្សរូបធំក្រឡេកមើលមកយើង ដែលស្រោបស្រប់ដោយលោហិត មានរបួសជាច្រើន ។ ហើយនៅទីបំផុត នាងព្យុគ្សនោះដើរចូលមកយ៉ាងអង់អាចកាត់មុខស្តេចព្រៃឯទៀត ។ សឹងមានតែស្នាមរបួសស្រោចខ្លួន ដែលយើងបានតស៊ូឲ្យបរាជ័យទៅ នាងព្យុគ្សយកមាត់លិទ្ធយ៉ាងថ្នមៗ ចំពោះធ្មេញចំនេរបស់យើង រួចនាងតាមមកនៅរួមរស់ស្នេហាជាមួយទីងយើងក្នុងព្រៃនោះទៅ ។ វដ្ដៈនៃការវិលកើតវិលស្លាប់ត្រឡប់ពីបានតបមកកាន់បានខ្ពស់ដូច្នេះឯង » ។

ហេតុដូច្នេះ ព្រះរាជកុមារត្រូវបានទៅព្រះសិទ្ធត្ថរាជកុមារដោយវេទនាសន្ទិកស ហើយនាគាលជ្លាយឬស្មូរមានដំណើរប្រែកែ (តើឬក៏ព្យាការគេលាលួ) បុណ្យអភិសេកសមរសក៏បានបាត់ធ្វើឡើង ឲ្យត្រឹមត្រូវតាម

ទំនៀមពួកសាកិយៈ ការមនៈមាសគេបានរៀបចាំងហើយ ព្រឹកបាន ក្រាលរៀបចំហើយ គេបានព្យួរមែងផ្កាកញ្ញាហ៍ពិតាន គេបានចង អំបោះខ្សែព្រះហស្តរបស់ក្សត្រក្សត្រី ហើយគេបានកាប់អំផ្អែមជាពីរ កំណាត់ គេបានបាចសាចអង្ករ និងទឹកអប់បណ្ដែតសារៃសំប៉ែងពីរ សារៃសលើទឹកដោះក្រហមហើយអណ្ដែតទៅជិតគ្នា ជាប្រផ្នូលល្អសឲ្យ ឃើញសេចក្ដីស្នេហា ថានឹងមានរហូតដល់ទៅស្លាប់ រួចក្សត្រក្សត្រី ស្វាមីភរិយាទាំងគូនាំគ្នាដើរប្រទក្សិណ ៧ ជុំហាន ជុំវិញព្រះភ្លើង ៣ ជុំ (តាមច្បាប់របៀបការរបស់ព្រាហ្មណ៍) គ្រឿងទេយ្យទាន ក៏ចាត់ចែង ចែកឲ្យដល់ពួកអ្នកបួសនិងពួកសមណ គ្រឿងសំណែនផ្សេងៗ គេក៏បាន នាំយកទៅបូជាតាមព្រះវិហារទាំងឡាយ នៅទីបំផុត គេបានធ្វើពិធីសូត្រ មន្ត រួចគេចងព្រះហស្តរបស់ក្សត្រក្សត្រីជាមួយគ្នា ។ កាលណោះ ព្រះរាជបិតារបស់ព្រះរាជកុមារីមានព្រះបន្ទូលថា « ព្រះរាជកុមារ ដ៏ ប្រសើរ! បុត្រីនេះពីដើមមកជារបស់យើង តាំងពីថ្ងៃនេះទៅ ត្រូវបាន ជារបស់អ្នកតែម្នាក់ឯង សុំឲ្យអ្នកមានមេត្តាដល់កុមារី ដែលបានផ្ញើជីវិត រួមនៅនឹងអ្នក » ។ តពីនោះ គេបានដើរហែព្រះនាងយសោធរា ដ៏ ឆើតឆោមទៅកាន់ព្រះស្វាមី ព្រមទាំងក្មេងក្មាត់ក្បែរគន្ធ គេបាន ប្រគល់ព្រះនាងដល់ព្រះហស្តព្រះសិទ្ធត្ថរាជកុមារ ហើយគូស្នេហាទាំង ពីរអង្គមានតែសេចក្ដីស្នេហាទៅវិញទៅមកយ៉ាងក្រៃលែងពេក » ។

ប៉ុន្តែសម្តេចព្រះវរបិតាមិនទាន់សព្វព្រះទ័យ ត្រឹមតែមានសេចក្តីស្នេហាប៉ុណ្ណោះទេ ទ្រង់បានឲ្យជាងកសាងកំពែងយ៉ាងតែងគួរឲ្យចាប់ចិត្តស្នេហាថែមទៀត មិនមានគូរប្រៀបផ្ទឹមបានលើពសុធា ជាកំពែងសម្រាប់ជាទីក្រសេមក្សាន្តព្រះទ័យនៃព្រះរាជកុមារ ; នៅជុំវិញកំពែងត្រង់កណ្តាលទីលានដ៏ធំទូលាយនោះ មានភ្នំ ១ ទៀតស្រអាក់ ដែលជាកំណើតស្ទឹងពេជ្ជាទី ខាងក្នុងទឹកធ្លាក់ចុះតាមតំណើតកំពូលហិមាលយ៉ា ដើម្បីនាំទឹកចង្អូរចូលទៅក្នុងអន្លង់គង្គា ធ្វើឲ្យមេគង្គាមានវាលធំ ៗ ឡើង ។ នៅទិសខាងត្បូង មានព្រៃអំពិលទន់ព្រៃកំពង់ ដ៏ដេរដាសទៅដោយផ្កាមានពណ៌ស្រស់ស្អាតចិញ្ចាំងព្រះរាជកំពង់ តែតែងមានសូរសំឡេងខ្យល់ដែលបក់មកពុះសូរតពេះដូចសូរយំយំសាវិកក្នុងស៊ុំទ្រមគុម្ពឈើ , នៅទិសខាងជើងមានកំពូលភ្នំធំៗ ប្រែប្រាងសំបុរសក្បូះ ក្នុងព្រំភ្នំហិមាលយ៉ា ហាក់ដូចជាគេលើកចំពោះក្រោកទប់ទ្រនាប់ដល់ផ្ទៃមេឃ គួរឲ្យអស្ចារ្យ ហើយចក្រកំឡែះព្រៃផ្កាត្រដែមដោយកំពូល ទីងជុំសិលាស្រួចៗ ខ្លះមូលខ្លះសំប៉ែត ខ្លះហោតសទ្ធិម ខ្លះជាដុំទឹកកកប្រែងប្រាង ខ្លះជាជ្រោះជ្រៅ ហើយមានទឹកឈូរហូរចុះទៅក៏មាន ធ្វើឲ្យកើតគំនិតគន្ធន់ខ្ពស់ឡើងត្រៃផត ដល់ទៅផ្ទៃមេឃ ហាក់ដូចជាបានសន្ទនាការជាមួយនឹងពួនទេវត្តា ៗ នៅពីខាងក្រោមហិមវះនោះ ដេរដាសទៅដោយព្រៃព្រឹក្សលតាវល្លិ ដែលបញ្ចេញក្លិនក្រអូបផ្ដុំដោយទឹកឈូរ ហើយចិញ្ចាំង

ស្រទំដោយទ័ពពពក , នា ក្រោមចុះមកទៀត មានគុម្ពដើមស្រល់ធំៗ ផ្សេងៗ ដាលំនៅនៃខ្លាខ្ទិន ចៀមព្រៃ ហើយលាន់ឮសូរសត្វខ្លែងយំរងំ ក្នុងព្រៃ , ចុះក្រោមបន្តទៀត ជាទីវាលស្មៅមានពណ៌ខៀវៗ ដូចជាព្រំ ដែលគេក្រាលនៅជើងអាសនៈព្រះ សម្រាប់គន្ធព្វសូត្រធម៌ថ្វាយបង្គំ ព្រះ ៗ នៅចំពីខាងមុខ ពួកជាងរំលឹករទាំនាសារ៍ ប្រាសាទ ១ យ៉ាងធំ លើជំពូលខ្ពស់ រូបគេសង់បញ្ចូល មានកំពែងសសរព័ទ្ធជុំវិញ , មានរូប បង្ហាញជារឿងកំណើតព្រះនាង ដូចជារូបព្រះត្រីស្នា: រូបទេពគន្ធព្វ នាងសីតា ហនុមាន នាងទ្រោបទី ហើយនៅលើស៊ុំក្លោងទ្វារគេ ឆ្លាក់រូបព្រះគណេស ទ្រង់ខ្លួនដំរីកង្ហែរ ដើម្បីសំដែងសេចក្តីបេះដូង ទ្រង់សេចក្តីចំរើន គុណូបការប្រយោជន៍ ។ ពេលបើដើរទៅតាមផ្លូវចក់ថ្ម នៃសួនឧទ្យានទឹងទ្វីប ចូលទៅដល់ទ្វារខាងក្នុងជាទ្វារថ្មកែវស្រកឡា ផ្កាកុលាប ហោជាងធ្វើពីឈើខ្មុំចន្ទន៍ នរណាក៏ធ្វើពីថ្មកែវស្រមោល ហើយទ្វារខ្ទមចន្ទន៍មានសង្កតទ្វារប្រដាប់ដោយត្បូងផ្សេងៗ ដើរលើងគួរ ទ្រេសប្បាយចិត្តក្នុងបន្ទប់ល្អផ្សេងៗ យ៉ាងល្អជើត ទីនបន្ទប់មានម្ជប់ ឯទីង កាលឡើងជណ្ដើរយ៉ាងល្អពៅ ហើយដើរកាត់រៀងជាថ្នាក់ៗ ទៅ ទើបមើលឃើញក្រៀងបន្ទប់ផ្សេងៗ ដែលមានពណ៌លាបថ្នាំ ហើយ សសរជាពួកៗ មានទឹកឈូកផ្កាឈូករៀងជាយគ្នា ឯក្រពាប់ដែលផុះ ផុតពីទឹកឡើងមក មានមច្ឆជាតិគួរឲ្យស្រលាញ់ នៅក្នុងការនៃរបរណៃ

មានសំបុរមាសសំបុរទៀត មានគុម្ពគេហៈមណ្ឌលវេល មានក្លាំងក្លួមធំ ត្រើបផ្កាកុលាបដែលមានក្លិនក្រអូប ហ្វូងបក្សីសំរុកផ្លូវផ្គួ ហើររកនា កណ្ដាលដើមត្នោត បក្សីព្រាបសំបុរទៀត សំបុរប្រផេះ ធ្វើសំបុកនៅ លើក្បាលសសរពណ៌មាសនៅលើវែនសិលាថ្មយក្ខក្នុងស្រះមាល មាន ហ្វូងបក្សីក្ងោកកោយកន្ទុយយ៉ាងល្អ ឯបក្សីក្រសាសំបុរសដូចទឹកដោះ ទីងទីទុយគូៗ ក៏រម៉ិលមើលបក្សីក្ងោកដោយអាការស្ងប់ស្ងៀម បក្សី សេកក្រហមក៏លោតផ្លោះពោះស៊ីផ្លែឈើពីផ្លែ១ ទៅផ្លែ១ បក្សីប្រទៃឡហើរ ទៅទំលើផ្កា១ទៅផ្កា១ ពួកជីងចក់តុកកែតូចសំដំឥតភ័យខ្លាចព្រួយបារម្ភ សត្វកំប្រុកនាំគ្នាចុះមកស៊ីភោជនាហារនៅទីនេះ ពីព្រោះគ្រប់ទីតំបន់ មានតែសេចក្តីស្ងប់ក្សេមក្សាន្ត ឯពស់ខ្មៅជាប្រផ្លុសក្រមន្ទិលសម្រាប់ ត្រកូល ក៏ដេកកំដៅខ្លួននៅកណ្ដាលថ្ងៃខាងក្រោមផ្កាច័ន្ទន៍ ក្បែរមាន ទីនោះ មានពួកពានរធ្លើបួកញ្ចៀកទៅរកហ្វូងក្អែក ។ ហើយនៅ កំណាត់ជាទីស្នេហាទាំងមូល ពេញទៅដោយពួកបម្រើដែលស្មោះត្រង់ ត្រាន់តែឲ្យសញ្ញាបន្តិច ក៏មានពួកមនុស្សម្នាទាត់ស្រស់បស់តែមក ទទួលបម្រើយ៉ាងរួសរាន់ តាំងនិយាយសំដីពិរោះ អ្នកបម្រើម្នាក់ៗ សឹង នាំគ្នាប្រឹងធ្វើឲ្យកើតសប្បាយរីករាយ តាំងចិត្តស្ងប់ស្ងាត់ដោយសេចក្តី គោរព ដើម្បីនាំជីវិតហ្លួងទៅរកសេចក្តីក្សេមក្សាន្ត ដូចជាទទេផ្កាមាន

ក្នុងដីពិសោធជានិច្ច ហើយព្រះនាងយសោធរា ជាព្រះពជ័ឪធ្វើឲ្យរាជ-
សំណាក់នេះ ប្រកបដោយសេចក្ដីត្រេកត្រអាលយ៉ាងក្រៃលែង ។

ប៉ុន្តែក្រៅអំពីក្បួនបន្ទប់កប់រយ៉ងផ្ដុំផ្គង់ នៅមានបន្ទប់សំងាត់ ១ ទៀត ដែលប្រកបដោយវេទនាយ៉ាងវិចិត្របៃត ដើម្បីជាទីសម្រាកអង្សស្រ័យ កាលទឹងដើរចូលទៅក្នុងបន្ទប់នេះ គោងដើរកាត់ទីលានសំងាត់ដែលនៅខាងក្នុងប្រាសាទនោះឯង តែជាទីលានស្រឡះ ត្រង់កណ្ដាលធ្វើពីថ្មកែវសំបុរស្អាតដូចទឹកដោះ មានជណ្ដើរឡើងទៅលើជាថ្មើមថ្ម មានបង្កាន់ដៃទាវេទនាជាក្បាច់ក្បូរប្រជាប់ប្រជាដោយថ្មកែវពណ៌ផ្សេងៗ យ៉ាងល្អ គួរឲ្យសប្បាយក្រៃម្នេះ កាលបើបានឈប់សម្រាកពាល់អស់ចិត្តក្នុងពជស្ថាននោះ ហាក់ដូចបានដើរលើទឹកខកក្នុងរបួរក្ដៅ រស្មីនៃសុរិយាចុះពន្លឺព្រាលផ្លៅ ចូលទៅតាមទ្វារទឹងបង្អោះពន្លឺស្រទន់ៗ មានពណ៌សដូចជាប្រាក់ សន្សំមមៗ បាក់ពន្លឺទៅជាស្រគាប់ ហាក់ដូចពន្លឺថ្ងៃបានឈប់លែងប្រែប្រួលក្លាយទៅជាពន្លឺសេហាទៅវិញ ព្រោះខាងក្នុងវាននេះ មានបន្ទប់ធំស្រឡះ ល្អត្រកាលវិសេសជាងទីដទៃៗ មានពន្លឺបង្អៀង គោមព្រឹមៗក្នុងក្រឡូង ចុះពន្លឺទៅតាមបង្អួចក្បូរម្ភ ហើយព្រះសន្ទិយាផ្កាយផ្កាយបរបាប់ទាស ព្រះវែងខបង្គំសុខ្ញុំព្រែងល្អផ្តិតប្តូងថ្ងៃថ្លា ដែលទឹងបើកបិទបានតែស្ត្រីណា ដែលមានរូបឆោមលើតប៉ុណ្ណោះនៅក្នុងនោះ ឥតមានអ្នកណាមួយអាចដឹងបានថា ជាវេលាយប់

ឬវេលាថ្ងៃទេ ព្រោះប្រទីបឈ្មោលាមានពន្លឺភ្លឺព្រោងព្រាតជានិច្ច សឹង
ភ្លឺច្បាស់ជាងវេលាថ្ងៃអរុណទើបរះ តែតែងពន្លឺ ត្រកាលជាងពន្លឺមាស
នៃអាទិត្យ១ម៉ឺន. ខ្យល់បក់មកក៏កើយរហើយសប្បាយជាងវេលាព្រឹក
តែត្រជាក់ជាងក្នុងយាមយប់ សំឡេងពិណាបទេងសាន់ព្រះឡើងទាំងយប់
ទាំងថ្ងៃ, ភោជនាហារដ៏មានរសជាតិសេរីមែងមានមកជានិច្ច មិនថាយប់
មិនថាថ្ងៃ ទាំងផ្លែឈើស្រស់ដោយទឹកសន្សើម គ្រឿងផឹកផ្សេងៗដោយ
ហិមៈនៃភ្នំហិមាលយ៉ា មេម្រាជ៏មានរសជាតិ ហើយដាក់ទឹកក្លិនក្នុងភាជនៈ
ដែលធ្វើពីកុលាបដ៏រ ទាំងយប់ទាំងថ្ងៃ សឹងមាននានរង្វាន់ដែលបានរើស
សម្រាំង ចាក់ថ្វាយទាំងយប់ទាំងថ្ងៃជានិច្ច ព្រមទាំងតូរ្យតន្ត្រី, លួងលោម
ប្រលោមឲ្យកើតសេចក្ដីស្នេហា ជាគ្រឿងដាស់ព្រះទ័យព្រះសិទ្ធត្ថ-
កុមារឲ្យភ្ញាក់រលឹកពីអារម្មណ៍សន្តិសុខ ហើយដឹកនាំព្រះវិញ្ញាណឲ្យធ្លាក់
ទៅនៅក្នុងកាមស្នេហាឡើងវិញ ដោយតន្ត្រីដែលព្រះល្វើងល្វើយ នៅ
កណ្ដាលបុប្ផា ឬដោយសូរសៀងចំរៀងដែលគួរឲ្យកើតតាមតណ្ហា
ហើយការរាំរែកជាទីតម្រេក ធ្វើតាមបន្ទាក់ ព្រមទាំងគងរនាំងទឹងក្លួង
បន្ទ្រន់បន្ទន់នៅកណ្ដើងនានរបាំ ឬតតាក់ធ្វើដៃ-ជើង ទិងស្បូរស័ព្ទសំឡេង
ពិណាខ្សែព្រាក់ ឯប្រេងឈ្នួសទឹងបម្រុកទឹងដែស្រងពណ៌ទៀតដុតអប់
ត្រឡប់ក្លិនផ្សាយពីដោះខ្លួនខ្លាយទៅ នាំឲ្យវិញ្ញាណរបស់ព្រះអង្គក្លិន

ហើយគេអញ្ជើញស្តេចឲ្យផ្ទំលើព្រះហត្ថព្រះនាងយសោធរា ព្រះសិទ្ធត្ថ-រាជកុមារទ្រង់សម្រាន្តព្រះនេត្រយ៉ាងបរិបូណ៌ តែទ្រង់ភ្ញាក់ភ្លាំងៗ តាំងអស់ ក្នុងលោកនេះ ៕

មួយវិញទៀត ព្រះមហាក្សត្រទ្រង់បញ្ជាថា នៅក្នុងកំពែងព្រះរាជវាំងនោះ មិនឲ្យអ្នកណាមួយនិយាយពីសេចក្តីស្លាប់ឡើយ ព្រមទាំងជរាស់ផង, សេចក្តីទុក្ខសោកសេចក្តីចង្អៀតចិត្តឬឈឺចាប់, នៅព្រះរាជស្ថាននោះ បើមាននាងណាមួយថយលំអុះ ក៏ឲ្យនាងមិនអាចលោកកំបាំងទេ នាងណាមានអាការដូច្នេះ ទើបុគ្គលជាឥតទោសក័យខ្លីសោះ ក៏ត្រូវតែបណ្តេញឲ្យចេញអំពីព្រះរាជវាំងភ្លាមស្តីនោះដែរ ដោយទ្រង់ស្រែកស្រណោះព្រះរាជកុមារ ទ្រង់ខ្លាចលស់សេចក្តីទុក្ខព្រួយព្រំរបស់នាងនោះៗ ហើយមានពួកញាតិវង្សទាំងពីកាក្យទោសយ៉ាងម៉ឺងម៉ាត់ចំពោះអ្នកដែលនិយាយអំពីទុក្ខសោកក្នុងលោកិយនេះ ដែលពេញទៅដោយលំបាកវេទនា យ៉ាងសាកសាស្ត្រក្រៃលែងសេចក្តីភិតភ័យជាដើម ប្រសិនបើមានសក់ស (ស្កូវ) តែ ១ សរសៃនៅលើក្បាលសក់របស់នាងបម្រើ ឬនាងស្នំណា ត្រូវតែបញ្ចូលក្បាលមានទោសក្បាត់ហើយចាប់លើលើ ព្រឹកព្រហាម ផ្កាកុលាបដែលស្រពោនហើយ ត្រូវរើសបន្តូលយកទៅបោលឲ្យអស់ ស្លឹកឈើងាប់ក៏ត្រូវបោសឲ្យអស់មិនឲ្យមាន បណ្តារបស់ចាស់ៗដែលនាំឲ្យកើតទុក្ខព្រួយ ត្រូវយកចេញឲ្យអស់ពីព្រះរាជស្ថាន

នេះ ព្រោះព្រះបិតាទ្រង់ត្រាស់ថា « ប្រសិនបើគេ (ព្រះបុត្រនេះ) តាំងនៅក្នុងបឋមវ័យ ឃ្លាតឆ្ងាយពីរបស់ដែលដឹកនាំឲ្យកើតសេចក្ដីសង្វេគ មិនចំរើនឡើងក្នុងញាណគតិដែលមិនទាន់ប្រាកដនោះហើយ ស្រមោលនៃជោគជ័យ គឺព្រះពោធិញ្ញាណក៏មិនទន់ខ្សោយចុះទៅ ហើយយើងនឹងបានឃើញគេជាទៅឆ្ងាយពីមានអានុភាពដ៏ក្រៃលែង ត្រូវនឹងគ្រប់គ្រងត្រួតត្រាទៅគ្រប់ៗ ប្រទេស (ចក្រពត្តិរាជ) ប្រសិនបើគេត្រូវការ ហើយគេនឹងជាម្ចាស់នៃក្សត្រទាំងឡាយ ដែលជាកិច្ចយសដ៏ធំធ្ងន់ក្នុងសម័យរបស់គេ » ។

ហេតុនេះ នៅជុំវិញនៃតំណាក់ស្នេហាដ៏ល្អវិចិត្រ ដែលមានសុខនៃកត្តគណ្ហ ជាគ្រឿងឃុំខាំង នឹងការក្រោមក្សត្រជាចំរើនការពារ ប៉ុន្តែឆ្ងាយពីការដែលគេបានឃើញនោះ ព្រះបិតាទ្រង់ចាត់ឲ្យសាងកំពែងយ៉ាងក្រាស់ មានទ្វារបីរយ មានសន្ធឹងទ្វារពីរ ក្នុងទ្វារនីមួយៗ ត្រូវប្រើមនុស្សពលរយនាក់សម្រាប់បើក ហើយខណៈដែលបើក មានឮសូរសំឡេងគគ្រឹកគ្រេងទៅឆ្ងាយ ប្រមាណកន្លះយោជន៍ ខាងក្រោយទ្វារនេះក៏មានទ្វារទីពីរទីបីបន្ទាប់ៗ គ្នាទៅទៀត គឺជាការដើម្បីនឹងចេញពីព្រះបរម្ស្ថានដ៏សុខសម្ភារនោះទៅ ត្រូវបើករលងទ្វារទាំង ៣ នោះមកជាមុន ទើបចេញទៅរួច ជាទ្វារដ៏ធំសំបើមមហិមាជាក់ស្ដែង (មានត)

មានសាវកសន្និបាត ៣ លើក ទី ១ មានព្រះខីណាស្រព ១០០ កោដិ ទី ២ មានព្រះខីណាស្រព ៩០ កោដិ ទី ៣ មានព្រះខីណាស្រព ៨០ កោដិ ព្រះជន្មាយុ ១ សែនឆ្នាំទើបបរិនិព្វាន ។

សម័យនោះ ព្រះលោកនាថរបស់យើងទ្រង់កើតជាតាបសឈ្មោះ មង្គល មានតេជះដ៏ខ្លាំងខ្លាំង ប្រកបដោយវេទអភិញ្ញាពល បានយកផ្លែព្រីង ថ្វាយព្រះពុទ្ធព្រះនាមសិទ្ធត្ថព្រះអង្គនោះ តាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

## ១៧ — ព្រះពុទ្ធតិស្ស:

ព្រះមាតានាមព្រះនាងបទុមា ព្រះបិតាជាក្សត្រព្រះនាមជនសន្ធ អគ្គមហេសីនាមព្រះនាងសុភទ្ទា ព្រះរាជបុត្រព្រះនាមអានន្ទ គង់នៅនគរឈ្មោះខេមកៈ ព្រះជន្មាយុ៧ពាន់ឆ្នាំ ទើបចេញបួសដោយសេះ ធ្វើទុក្ករកិរិយា ៨ខែ ដើមធ្នង់ជាពោធិព្រឹក្ស អគ្គសាវក ២ រូប គឺព្រហ្មទេវៈ ១ ឧទយៈ ១ ឧបដ្ឋាក ១ រូប ឈ្មោះសមង្គៈ អគ្គសាវិកា ២ រូប គឺផុស្សា ១ សុទត្តា ១ មានសាវកសន្និបាត ៣ លើក ទី ១ មានព្រះ

ខីណាស្រព ១ សែនអង្គ ទី២ មានព្រះខីណាស្រព ៩០ សែនអង្គ ទី៣ មានព្រះខីណាស្រព ៨០ សែនអង្គ ព្រះជន្មាយុ ១ សែនឆ្នាំ ទើបបរិនិព្វាន ។

សម័យនោះ ព្រះមហាមុនីរបស់យើង ទ្រង់កើតជាក្សត្រព្រះនាមសុជាត បានលះបង់រាជសម្បត្តិដ៏ច្រើន ហើយទៅបួសជាឥសី កាលដែលទ្រង់ព្រះផ្នួសហើយ បានឮថា ព្រះពុទ្ធព្រះនាមតិស្សត្រាស់ឡើងក្នុងលោក ក៏ត្រេកអររីករាយ បានយកផ្កាមន្ទារព្រឹក្ស ផ្កាឈូកនិងផ្កាបារិច្ឆត្តព្រឹក្សជាទិព្វបត់ថ្វាយ ហើយឈរប៉ាំងផ្កាពីខាងលើ ព្រះពុទ្ធតិស្សទ្រង់ទាយថា ឥសីនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

## ១៨–. ព្រះពុទ្ធបុស្ស

ព្រះមាតានាមព្រះនាងសិរិមា ព្រះបិតាជាក្សត្រព្រះនាមជយសេន អគ្គមហេសីនាមព្រះនាងកិសាគោតមី ព្រះរាជបុត្រព្រះនាមអានន្ទ ក្នុងកាសិកនគរ ព្រះជន្មាយុ ៩ ពាន់ឆ្នាំទើបចេញបព្វជ្ជាដោយយានដំរី ធ្វើទុក្ករកិរិយា ៧ ថ្ងៃ ដើមឧទ្ទតព្រៃជាពោធិព្រឹក្ស អគ្គសាវក ២ រូប គឺសុរក្ខិត ១ ធម្មសេន ១ ឧបដ្ឋាក ១ រូប ឈ្មោះសភិយ អគ្គសាវិកា ២ រូប គឺចាលា ១ ឧបចាលា ១ មានសាវកសន្និបាត ៣ លើក ទី១ មានព្រះខីណាស្រព ៦០ សែនអង្គ ទី២ មានព្រះខីណាស្រព ៥០ សែនអង្គ

ទី ៣ មានព្រះខីណាស្រព ៦០ សែនអង្គ  ព្រះជន្មាយុ ៩ ហ្មឺនឆ្នាំ  ទើបបរិនិព្វាន ។

សម័យនោះ  ព្រះអរហំសម្ពុទ្ធរបស់យើង  ទ្រង់កើតជាក្សត្រព្រះនាមវិជិត  ទ្រង់លះរាជ្យចោល  ហើយចេញទៅទ្រង់ព្រះផ្នួសក្នុងសំណាក់ព្រះពុទ្ធផុស្សនោះ  ព្រះអង្គទាយថា  ភិក្ខុនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

## ១៩–. ព្រះពុទ្ធវិបស្សី

ព្រះមាតានាមព្រះនាងពន្ធុមតី  ព្រះបិតាជាក្សត្រព្រះនាមពន្ធុម  អគ្គមហេសី  នាមព្រះនាងសុទស្សនា  ព្រះរាជបុត្រព្រះនាមសមវត្តក្ខន្ធ  ក្នុងនគរពន្ធុមតី  ព្រះជន្មាយុ ៨ ពាន់ឆ្នាំ  ទើបចេញបព្វជ្ជាដោយយានរថ  ធ្វើទុក្ករកិរិយា ៨ ខែ ដើមប្រៀងជាពោធិព្រឹក្ស  អគ្គសាវ័ក ២ រូប  គឺខណ្ឌ ១ តិស្សនាម ១ ឧបដ្ឋាក ១ រូប  ឈ្មោះអសោក  អគ្គសាវិកា ២ រូប  គឺចន្ទា ១ ចន្ទមិត្តា ១ មានសាវកសន្និបាត ៣ លើក  ទី ១ មានព្រះខីណាស្រព ៦៨ សែនអង្គ  ទី ២ មានភិក្ខុ ១ សែនអង្គ  ទី ៣ មានភិក្ខុ ៨ ហ្មឺនអង្គ  ព្រះជន្មាយុ ៨ ហ្មឺនឆ្នាំ  ទើបបរិនិព្វាន ។

សម័យនោះ  ព្រះលោកនាថរបស់យើងទ្រង់កើតជាស្តេចនាគ  ឈ្មោះអតុល  មានរិទ្ធិច្រើនមានបុណ្យរុងរឿង  មាននាគបរិវារច្រើនសែន  ចូលទៅគាល់ព្រះពុទ្ធវិបស្សី  ហើយប្រគំដោយតូរ្យតន្ត្រីទិព្វថ្វាយ

ហើយប្រគេនគាំងមាសដល់ព្រះពុទ្ធអង្គនោះ ព្រះអង្គទ្រង់ទាយថា ស្ដេចនាគនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

## ២០ – ព្រះពុទ្ធសិខី

ព្រះមាតានាមព្រះនាងបភាវតី ព្រះបិតាជាក្សត្រព្រះនាមអរុណ អគ្គមហេសីនាមព្រះនាងសព្វកាមា ព្រះរាជបុត្រព្រះនាមអតុល ក្នុងនគរអរុណវតី ព្រះជន្មាយុ ៧ ពាន់ឆ្នាំ ទើបចេញបព្វជ្ជា ដោយយានដំរី ធ្វើទុក្ករកិរិយា ៨ ខែ ដើមស្វាយសជាពោធិព្រឹក្ស អគ្គសាវ័ក ២ រូប គឺ អភិភូ ១ សម្ភវៈ ១ ឧបដ្ឋាក ១ រូបឈ្មោះខេមង្ករ អគ្គសាវិកា ២ រូប គឺ មខិលា ១ បទុមា ១ មានសាវ័កសន្និបាត ៣ លើក ទី ១ មានភិក្ខុជាខីណាស្រព ១ សែនអង្គ ទី ២ មានភិក្ខុ ៨ ហ្មឺនអង្គ ទី ៣ មានភិក្ខុ ៧ ហ្មឺនអង្គ ព្រះជន្មាយុប្រមាណ ៧ ហ្មឺនឆ្នាំ ទីបបរិនិព្វាន ។

សម័យនោះ ព្រះជិនស្រីរបស់យើងទ្រង់កើតជាស្ដេចព្រះនាមអរិន្ទមៈ បានប្រគេនចង្ហាន់ដល់សង្ឃមានព្រះពុទ្ធជាប្រធាន ហើយតាក់តែងយានដំរីប្រគេនដល់ព្រះសម្ពុទ្ធព្រះនាមសិខី ព្រះអង្គទាយថា ព្រះជាអង្គនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

## ២១ – ព្រះពុទ្ធវេស្សភូ

ព្រះមាតានាមព្រះនាងយសវតី ព្រះបិតាជាក្សត្រព្រះនាមសុប្បតិតៈ អគ្គមហេសីនាមព្រះនាងសុចិត្តា ព្រះរាជបុត្រព្រះនាមសុប្បពុទ្ធ

ក្នុងនគរឈ្មោះអនោមៈ ព្រះជន្មាយុ ៦ ពាន់ឆ្នាំ ទើបចេញបព្វជ្ជាដោយព្រះសិវិកា ធ្វើទុក្ករកិរិយា ៦ ខែ ដើមរាំងធំជាពោធិព្រឹក្ស អគ្គសាវក ២ រូប គឺ សោណៈ ១ ឧត្តរៈ ១ ឧបដ្ឋាក ១ រូបឈ្មោះឧបសន្តៈ អគ្គសាវិកា ២ រូប គឺ កមា ១ សមាលា ១ មានសាវកសន្និបាត ៣ លើក ទី ១ មានព្រះខីណាស្រព ៨០ ពាន់កោដិ ទី ២ មានភិក្ខុ ៧០ ពាន់រូប ទី ៣ មានភិក្ខុ ៦០ ពាន់រូប ព្រះជន្មាយុប្រមាណ ៦០ ពាន់ឆ្នាំ ទើបបរិនិព្វាន ។

សម័យនោះ ព្រះសុគតរបស់យើងទ្រង់កើតជាស្ដេចព្រះនាមសុទស្សនៈ បានប្រគេនចង្ហាន់និងសំពត់ដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ហើយបួសក្នុងសំណាក់ព្រះជិនស្រីអង្គនោះ ព្រះពុទ្ធវេស្សភូទ្រង់ទាយថា ស្ដេចនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

## ២២—. ព្រះពុទ្ធកកុសន្ធៈ

មាតាឈ្មោះនាងវិសាខា បិតាឈ្មោះអគ្គិទត្តព្រាហ្មណ៍ ភរិយាឈ្មោះនាងរោចិនី បុត្រឈ្មោះឧត្តរ ក្នុងនគរឈ្មោះខេមវតី ព្រះជន្មាយុ ៤ ពាន់ឆ្នាំ ទើបចេញបព្វជ្ជាដោយយានរថ ធ្វើទុក្ករកិរិយា ៨ ខែ ដើមជ្រៃសជាពោធិព្រឹក្ស អគ្គសាវក ២ រូប គឺវិធុរ ១ សញ្ជីវនាម ១ ឧបដ្ឋាក ១ រូប ឈ្មោះពុទ្ធិជ អគ្គសាវិកា ២ រូប គឺសាមា ១ ចម្បានាមា ១ មាន

សាវកសន្និបាតតែ ១ លើក មានព្រះខីណាស្រព ៤០ ពាន់អង្គ ព្រះជន្មាយុប្រមាណ ៤០ ពាន់ឆ្នាំទើបបរិនិព្វាន ៖

សម័យនោះ ព្រះសុគតរបស់យើងទ្រង់កើតជាក្សត្រ ព្រះនាមខេមៈ បានប្រគេនទានដ៏ប្រសើរ មានបាត្រ ចីវរ ថ្នាំបន្តក់ ឈើតែមជាដើមដល់ព្រះពុទ្ធកកុសន្ធព្រមទាំងព្រះសង្ឃ ព្រះពុទ្ធកកុសន្ធទ្រង់ទាយថា ព្រះកជានេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

## ២៣ –. ព្រះពុទ្ធកោនាគមនៈ

មាតាឈ្មោះនាងឧត្តរា បិតាឈ្មោះយញ្ញទត្តព្រាហ្មណ៍ ភរិយាឈ្មោះនាងរុចិគត្តា បុត្រឈ្មោះសត្ថវាហ ក្នុងនគរសោភវតី ព្រះជន្មាយុ ៣ ពាន់ឆ្នាំ ទើបចេញបព្វជ្ជាដោយយានដំរី ធ្វើទុក្ករកិរិយា ៦ ខែ ដើមឧទុម្ពរ ជាពោធិព្រឹក្ស អគ្គសាវក ២ រូប គឺភិយ្យោស ១ ឧត្តរ ១ ឧបដ្ឋាក ១ រូប ឈ្មោះសោត្ថិជ អគ្គសាវិកា ២ រូប គឺនាងសមុទ្រា ១ នាងឧត្តរា ១ មានសាវកសន្និបាតតែ ១ លើក មានភិក្ខុជាព្រះខីណាស្រព ៣ ហ្មឺនអង្គ ព្រះជន្មាយុប្រមាណ ៣ ហ្មឺនឆ្នាំ ទើបបរិនិព្វាន ។

សម័យនោះ ព្រះគោតមសម្ពុទ្ធរបស់យើងទ្រង់កើតជាក្សត្រ ព្រះនាមបព្វតៈ បានយាងទៅគាល់ព្រះសម្ពុទ្ធ ហើយស្តាប់ធម៌ទេសនាដ៏ប្រសើរ បានប្រគេនទានដ៏ប្រសើរគឺបាត្រសំពត់កោសេយ្យសំពត់កម្ពលជាដើម

ដល់ព្រះសង្ឃព្រមទាំងព្រះពុទ្ធ ។ ព្រះពុទ្ធកោនាគមនៈទ្រង់ទាយថា ព្រះរាជាអង្គនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

## ២៤–. ព្រះពុទ្ធកស្សប

មាតាឈ្មោះធនវតី បិតាជាព្រាហ្មណ៍ឈ្មោះព្រហ្មទត្ត ភរិយាឈ្មោះសុនន្ទា បុត្រឈ្មោះវិជិតសេន ក្នុងនគរពារាណសី ព្រះជន្មាយុ ២ ពាន់ឆ្នាំ ទើបចេញបព្វជ្ជាដោយប្រាសាទ ធ្វើទុក្ករកិរិយា ៧ ថ្ងៃ ដើមរៃជ្រៃជាពោធិព្រឹក្ស អគ្គសាវក ២ រូប គឺតិស្ស ១ ភារទ្វាជ ១ ឧបដ្ឋាក ១ រូប ឈ្មោះសព្វមិត្ត អគ្គសាវិកា ២ រូប គឺនាងអនុលា ១ ឧរុវេលា ១ មានសាវកសន្និបាតតែ ១ លើក មានព្រះខីណាស្រព ២ ពាន់អង្គ ព្រះជន្មាយុ ២ ហ៊ឺនឆ្នាំ ទើបបរិនិព្វាន ។

គ្រានោះ ព្រះសក្យមុនីរបស់យើងទ្រង់កើតជាមាណព ឈ្មោះជោតិបាល ជាអ្នករៀនមន្តចេះចប់ត្រៃវេទ ស្គាល់ផែនដីនិងអាកាសចេះ ធីតារពារវេទ ។ គ្រានោះ ឃដិការជាឧបដ្ឋាករបស់ព្រះពុទ្ធកស្សប បាននាំជោតិបាលមាណព ចូលទៅគាល់ព្រះជិនស្រីព្រះនាមកស្សប ហើយបួសក្នុងសំណាក់ព្រះជិនស្រីនោះ ជាអ្នកមានព្យាយាមក្លៀវឈ្លាស ក្នុងវត្តបប់ បានបំពេញកិច្ចក្នុងសាសនាព្រះពុទ្ធកស្សបនោះ ព្រះអង្គទ្រង់ឃើញសេចក្ដីអស្ចារ្យខ្លាំង ទើបទ្រង់ព្យាករណ៍ថា ជោតិបាលភិក្ខុនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

## ២៥ – ព្រះពុទ្ធគោតម

ព្រះមាតានាមព្រះនាងមហាមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ អគ្គមហេសីនាមព្រះនាងយសោធរា ព្រះរាជបុត្រព្រះនាមរាហុល ក្នុងនគរកបិលវត្ថុ ព្រះជន្មាយុ ២៩ ឆ្នាំ ទើបចេញបព្វជ្ជា ដោយយានសេះ ធ្វើទុក្ករកិរិយា ៦ ឆ្នាំ ដើមពោធិ៍ជាពោធិព្រឹក្ស អគ្គសាវក ២ រូប គឺ កោលិត ១ ឧបតិស្ស ១ ឧបដ្ឋាក ១ រូប ឈ្មោះអានន្ទ អគ្គសាវិកា ២ រូប គឺនាងខេមា ១ ឧប្បលវណ្ណា ១ មានសាវកសន្និបាតតែ ១ លើក មានព្រះវិណាស្រែត ១៦៨០ អង្គ ព្រះជន្មាយុប្រមាណ ១០០ ឆ្នាំ ទើបបរិនិព្វាន ។

ក្នុងសៀវភៅពុទ្ធប្បវត្តិសម្រាយថា ព្រះមហាស្ដារបស់យើងទ្រង់បរិនិព្វានក្នុងព្រះជន្មាយុ ៨០ ឆ្នាំ គឺព្រះជន្ម ២៩ ឆ្នាំចេញបព្វជ្ជា ធ្វើទុក្ករកិរិយា ៦ ឆ្នាំ បានត្រាស់អនុត្តរសម្ពោធិ ហើយបំពេញពុទ្ធកិច្ច ៤៥ ឆ្នាំ ទើបបរិនិព្វាន ប្រមូលប្រវ៉ាព្រះជន្ម ៨០ ឆ្នាំគត់ តែក្នុងសុត្តន្តបិដក ខុទ្ទកនិកាយពុទ្ធវង្ស ព្រះពុទ្ធទាំង ២៤ ព្រះអង្គទ្រង់ព្យាករណ៍ថា ព្រះលោកនាថរបស់យើងមានព្រះជន្ម ១០០ ឆ្នាំ ។

# អំពីការតាំងចៅអធិការថ្មី

(គិតពីឆ្នាំ ១៩៤៨)

សញ្ញាប័ត្រលេខ ១៩ ចុះថ្ងៃ ៥ រោច ខែចេត្រ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ មាស-ឌុន នាមឆាយា សុវណ្ណកេត្រ កើតឆ្នាំថោះ អាយុ ៣៤ ឆ្នាំ វស្សា ១៣ ជាចៅអធិការវត្តព្រែកតាមាក ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្ដាល កណ្ដាល ។

សញ្ញាប័ត្រលេខ ២៧ ចុះថ្ងៃ ១១ កើត ខែពិសាខ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ជួន-លាន នាមឆាយា ព្រហ្មជោតកេត្រ កើតឆ្នាំចអាយុ ៣៩ ឆ្នាំ វស្សា ១៧ ជាចៅអធិការវត្តព្រស្គា ឃុំព្រៃពៅ ស្រុកពារាំង ព្រៃវែង ។

សញ្ញាប័ត្រលេខ ២៨ ចុះថ្ងៃ ១១ កើតខែពិសាខ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ចក់-មៅ នាមឆាយា កាលកេត្រ កើតឆ្នាំចអាយុ ៣៩ ឆ្នាំ វស្សា ១៨ ជាចៅអធិការវត្តសថ៍ ឃុំព្រែកពៅ ស្រុកពារាំង ព្រៃវែង ។

សញ្ញាប័ត្រលេខ ២៩ ចុះថ្ងៃ ១១ កើតខែពិសាខ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ គួច-យន់ នាមឆាយា ពុទ្ធជោត កើតឆ្នាំឆ្លូវអាយុ ៤៨ ឆ្នាំ វស្សា ២៧ ជាចៅអធិការវត្តជ្រៃ ឃុំព្រៃស្រឡិត ស្រុកពារាំង ព្រៃវែង ។

សញ្ញាប័ត្រលេខ ៣០ ចុះថ្ងៃ ១១ កើត ខែពិសាខ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ប៊ូ-ក៉េន នាមធាយាឥន្ទជោត កើតឆ្នាំមមីអាយុ ៣១ ឆ្នាំ វស្សា ១០ ជាចៅអធិការវត្តពារាំង ឃុំកប ស្រុកពារាំង ព្រៃវែង ។

សញ្ញាប័ត្រលេខ ៣១ ចុះថ្ងៃ ១១ កើតខែពិសាខ ឆ្នាំជូតសម្រិទ្ធិស័ក តាំងលោកគ្រូជា-ទុះ នាមធាយា មុត្តាបញ្ញោ កើតឆ្នាំរកាអាយុ ៤០ ឆ្នាំ វស្សា ១៨ ជាចៅអធិការវត្តអន្ទង់ដៃ ឃុំព្រែកដៃ ស្រុកព្រៃវែង ព្រៃវែង ។

សញ្ញាប័ត្រលេខ ៣២ ចុះថ្ងៃ ១១ ៦ ឆ្នាំជូតសម្រិទ្ធិស័ក តាំងលោកគ្រូ គិម-ស៊ុយ នាមធាយា មង្គលបញ្ញោ កើតឆ្នាំថោះ អាយុ ៤៦ ឆ្នាំ វស្សា ២៤ ជាចៅអធិការវត្តព្រៃទំមូង ឃុំគគ្រុំ ស្រុកពារាំង ព្រៃវែង ។

សញ្ញាប័ត្រលេខ ៣៣ ចុះថ្ងៃ ១១ ៦ ឆ្នាំជូតសម្រិទ្ធិស័ក តាំងលោកគ្រូ សូរ-ឌុយ នាមធាយា សុវណ្ណកេតុ កើតឆ្នាំថោះអាយុ ៣៤ ឆ្នាំ វស្សា ១៣ ជាចៅអធិការវត្តតាម៉ិញ ឃុំស្មោង ស្រុកកំចាយមារ ព្រៃវែង ។

សញ្ញាប័ត្រលេខ ៣៤ ចុះថ្ងៃ ១១ ៦ ឆ្នាំជូតសម្រិទ្ធិស័ក តាំងលោកគ្រូ និន-ទិម នាមធាយា កេសរបញ្ញោ កើតឆ្នាំរោងអាយុ ៥៧ ឆ្នាំ វស្សា ៣៥ ជាចៅអធិការវត្តមង្គលស្បៀយោពម ឃុំព្រែកដៃ ស្រុកព្រៃវែង ខែត្រព្រៃវែង ។

សញ្ញាបត្រលេខ ៣៩ ចុះថ្ងៃ ១២ ៦ ឆ្នាំជូតសម្រិទ្ធិស័ក កាន់លោកគ្រូ ឌុក-ឌុច នាមឆាយា បញ្ញាជោត កើតឆ្នាំជូតអាយុ ៧៣ ឆ្នាំ វស្សា ៥៤ ជាចៅអធិការវត្តសាការនតេជោ ឃុំលេខ ៣ ក្រុងភ្នំពេញ ។

សញ្ញាបត្រលេខ ៤០ ចុះថ្ងៃ ៧ ៦ ឆ្នាំជូតសម្រិទ្ធិស័ក កាន់លោកគ្រូ ម៉ម-មួន នាមឆាយាសុធម្មោ កើតឆ្នាំ ១៩០៧ អាយុ ៣១ ឆ្នាំ វស្សា ១០ ជាចៅអធិការវត្តព្រៃញ៉ៅ ឃុំព្រៃញ៉ៅ ស្រុកពារាំង ខេត្តព្រៃវែង ។

សញ្ញាបត្រលេខ ៤១ ចុះថ្ងៃ ៧ ៦ ឆ្នាំជូតសម្រិទ្ធិស័ក កាន់លោកគ្រូ យិម នាមឆាយាបទុមសុវណ្ណមុនី កើតឆ្នាំរកាអាយុ ៥២ ឆ្នាំ វស្សា ៣១ ជាចៅអធិការវត្តព្រៃសំឡាញ ឃុំគោ ស្រុកពារាំង ខេត្តព្រៃវែង ។

សញ្ញាបត្រលេខ ៤៧ ចុះថ្ងៃ ៧ ៦ ឆ្នាំជូតសម្រិទ្ធិស័ក កាន់លោកគ្រូ ម៉ុង-មូល នាមឆាយា សុវណ្ណបញ្ញា កើតឆ្នាំ ១៨៩៦ អាយុ ៦២ ឆ្នាំ វស្សា ៤៣ ជាចៅអធិការវត្តមន្ត្រី ឃុំមន្ត្រី ស្រុករមាសហែក ខេត្តស្វាយរៀង ។

សញ្ញាបត្រលេខ ៤៨ ចុះថ្ងៃ ៧ ៦ ឆ្នាំជូតសម្រិទ្ធិស័ក កាន់លោកគ្រូ គិម-ពៅ នាមឆាយា ធម្មកេសរ កើតឆ្នាំ ១៩២២ អាយុ ២២ ឆ្នាំ វស្សា ៦ ជាចៅអធិការវត្តស្វាយជុប ឃុំមន្ត្រី ស្រុករមាសហែក ខេត្តស្វាយរៀង។

សញ្ញាប័ត្រលេខ ៤៩ ចុះថ្ងៃ ៗ ៦ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ណុប - ឌុល នាមនាយាធម្មគ្រោ កើតឆ្នាំមមែ អាយុ ៤២ ឆ្នាំ វស្សា ២០ ជាចៅអធិការវត្តត្រពាំងព្រីង ឃុំអង្គព្រះស្រែ ស្រុកមោងឫស្សីហោក ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៥០ ចុះថ្ងៃ ៗ ៦ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ហៃ - គុន នាមនាយា សិរីបញ្ញាថេរ កើតឆ្នាំមមី អាយុ ៤៣ ឆ្នាំ វស្សា ២១ ជាចៅអធិការវត្តប្រាសាទ ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៥១ ចុះថ្ងៃ ៧ កើតខែពិសាខ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ខេព - ឃិន នាមនាយាព្រហ្មរក្ខិតោ កើតឆ្នាំវក អាយុ ២៩ ឆ្នាំ វស្សា ៧ ជាចៅអធិការវត្តមជ្ឈិមវន ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ៥២ ចុះថ្ងៃ ៨ កើតខែពិសាខ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ប៉ុល - ទិន នាមនាយា ជោតគ្រោ កើតឆ្នាំជូត អាយុ ៤៩ ឆ្នាំ វស្សា ២៧ ជាចៅអធិការវត្តកំពង់ធំ ឃុំកំពង់ធំ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៥៣ ចុះថ្ងៃ ៨ កើតខែពិសាខ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ប៊ូ - លៀង នាមនាយា ធម្មសត្ថា កើតឆ្នាំជូត អាយុ ៤៨ ឆ្នាំ វស្សា ២៦ ជាចៅអធិការវត្តសង់យ៉ាំង ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៩៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូគង់-ជិន នាមធាយា បញ្ញាវិរិយៈ កើតឆ្នាំរោង អាយុ ៣៣ វស្សា ១២ ជាគ្រូសូត្រស្តាំវត្តសន្ធិយ៉ាន ឃុំកាំងត្រសាំង ស្រុកសង្កែ ខេត្របាត់ដំបង ។

សញ្ញាប័ត្រលេខ ៩៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូនៅ-ទៀត នាមធាយាធម្មសារត្ថេរ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១១ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ៩៦ ចុះថ្ងៃ ១១ កើតខែពិសាខ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូអ៊ុក-ផន នាមធាយា ឥន្ទត្ថេរ កើតឆ្នាំជូត អាយុ ២៤ វស្សា ៣ ជាគ្រូសូត្រស្តាំ វត្តព្រៃខ្វិន ឃុំលាច ស្រុកភ្នំក្រវាញ ខេត្រពោធិ៍សាត់ ។

សញ្ញាប័ត្រលេខ ៩៣ ចុះថ្ងៃព្រហស្បតិ៍ ២ កើត ខែជេស្ឋ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ភាយ-លឿន នាមធាយាព្រហ្មបញ្ញោ កើតឆ្នាំថោះ អាយុ ៥៨ វស្សា ៣៧ ជាព្រះគ្រូវិបស្សនាញាណ វត្តពោធិក-យារាម ឃុំលេខ ៧ ក្រុងភ្នំពេញ ។

សញ្ញាប័ត្រលេខ ៩៤ ចុះថ្ងៃចន្ទ ១ កើត ខែជេស្ឋ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ យិម-ឈឿម នាមធាយាសុវណ្ណោ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១៣ ជាចៅអធិការវត្តបន្ទាយចុងស្រី ឃុំត្រពាំងធំ ស្រុកសូទ្រនិគម ខេត្រសៀមរាប ។

សញ្ញាប័ត្រលេខ ៩៥ ចុះថ្ងៃសុក្រ ១ រោច ខែជេស្ឋ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ទៀន-ឡោក កើតឆ្នាំរកា អាយុ ៥៤ វស្សា ៣៧

ជាចៅអធិការវត្តគគរពោធិ៍ ឃុំព្រែកដីក្រាន ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៩៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហ៊ុយ-ប៊ុម នាមឆាយាធម្មបិដក កើតឆ្នាំខាល អាយុ ..៩ វស្សា ៧ ជាគ្រូសូត្រនៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩៧ ចុះថ្ងៃសុក្រ ៣ កើត ខែអាសាធ ឆ្នាំជូត សំរិទ្ធិស័ក តាំងលោកគ្រូ ណន់-ខៃ នាមឆាយាសរធម្មជោត កើតឆ្នាំកុរ អាយុ ២៦ វស្សា ៥ ជាចៅអធិការ វត្តប្រជុំសាគរ ឃុំលេខ ៧ ជ្រោយចង្វា ក្រុងភ្នំពេញ ។

សញ្ញាប័ត្រលេខ ៩៨ ចុះថ្ងៃអង្គារ ៦ កើត ខែអាសាធ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ វង់-ប៉ាន នាមឆាយា សុវណ្ណជោត កើតឆ្នាំច អាយុ ៥០ វស្សា ២៦ ជាចៅអធិការ វត្តទួលអណ្ដែត ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៩៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខៃ-ទុក នាមឆាយាព្រហ្មស័ កើតឆ្នាំច អាយុ ២៧ វស្សា ៦ ជាចៅអធិការ វត្តពោធិ៍ ឃុំព្រះមេ ស្រុកជាំក្សាន្ត ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ១០២ ចុះកាលបរិច្ឆេទដដែលតាំងលោកគ្រូ មាស-សុខ នាមឆាយា សសទ្ធម្ម កើតឆ្នាំច អាយុ ៧៥ វស្សា ៥៣ ជាចៅអធិការវត្តព្រះឥន្ទ្រទន់ ឃុំភូមិថ្មី ស្រុកកែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ១០៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ថាច់-ព្រំ នាមឆាយា ធម្មជោត កើតឆ្នាំវក អាយុ ៤៤ វស្សា ២០ ជាចៅអធិការវត្តសុវណ្ណគិរី ឃុំ· ស្រុកចែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ១០៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅ-ស៊ួរ នាមឆាយាធម្មគោរ កើតឆ្នាំឆ្លូវ អាយុ ៣៦ វស្សា ១៥ ជាចៅអធិការវត្តសិលាទិមិត្ត ឃុំកូវិថី ស្រុកចែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ១០៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ថាច់-ណម នាមឆាយាធម្មវិនយ កើតឆ្នាំច អាយុ ២៧ វស្សា ៦ ជាចៅអធិការវត្តសំពៅកែវ ឃុំពើក ស្រុកចែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ១០៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រំ-ចាន់ នាមឆាយាធម្មគោរ កើតឆ្នាំកុរ អាយុ ២៦ វស្សា ៤ ជាចៅអធិការវត្តខ្សែ ឃុំព្រាប ស្រុកចែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ១០៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឈួន-អ៊ុល នាមឆាយាធម្មបញ្ញោ កើតឆ្នាំជូត អាយុ ២៥ វស្សា ៤ ជាចៅអធិការវត្តជួលនិមិត្ត ឃុំម្លូព្រៃ ស្រុកចែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ១០៨ ចុះថ្ងៃព្រហស្បតិ៍ ៨កើត ខែអាសាឍ ឆ្នាំជូត សំរិទ្ធិស័ក តាំងលោកគ្រូ នង់-សុខ នាមឆាយាឥន្ទបញ្ញោ កើតឆ្នាំថោះ អាយុ ៤៦ វស្សា ១៤ ជាចៅអធិការវត្តគុក ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ។

(មានត)